សាធារណរដ្ឋប្រជាមានិតកម្ពុជា

# កូលីកំនែន

## ថ្នាក់ទី ១១

ក្រសួងអប់រំ

# អារម្ភកថា

រឿងគូលីកំនែន និពន្ធឡើងនៅខែសីហាឆ្នាំ១៩៥៦ ក្នុងសម័យកាលដែលប្រទេសកម្ពុជាបាន ទទួលឯករាជ្យតាមសេចក្តីសំរេចរបស់សន្និសីទ សឺណែវ នាឆ្នាំ១៩៥៤ ក្រោយពីបរាជ័យភាពរបស់ អាណានិគមបារាំងនៅ ឌៀន បៀនភូ ។ ក្នុងគ្រានោះចលនាតស៊ូរបស់យើង ឋិននៅក្រោមការ ដឹកនាំរបស់បក្សប្រជាជនខ្មែរ ដែលវាយស្របជាមួយចលនាអព្យាក្រឹតរង់ចាំឪកាសហុចអោយនឹង វាយរំលំរបបពាក់កណ្តាលសក្តិភូមិ គហបតីដណ្តើមយករដ្ឋអំនាច ។

ដំនើររឿង គុលីកំនែន បានបំផុសអោយឃើញព្រឹត្តិការណ៍សំខាន់ក្នុងសម័យអាណានិគម ដូចជាកំនែនរបស់ផាស៊ីលជប៉ុនមកលើប្រជាជនកម្ពុជា ដើម្បីធ្វើវាយយន្តហោះអោយពួកវា ។ សភាពការណ៍ធ្ងន់ធ្ងរនៅពេលនោះ ក្រៅពីទំងន់ទុក្ខដោយការជិះជាន់សង្កត់សង្កិនចំរាញ់យក ប្រយោជន៍ពីសំនាក់ពួកបារាំង ជប៉ុន មកលើប្រជាជនយើង នៅមានទំងន់មួយទៀត ដែលសង្កត់ ប្រជាពលករខ្លាំងណាស់ គឺអំពើយង់ឃ្នងនៃពួកឆ្កែបំរើដាច់ថ្លៃរបស់ពួកអាណានិគម ។ ពួកនេះមិន ញញើតនឹងបង្កការភ័យខ្លាច វិនាសកម្ម មហន្តរាយដល់ប្រជាជនឯងទេ ដើម្បីផ្គាប់ចិត្តចៅហ្វាយវា។

ក្រោយពីអាណានិគមចាស់បារាំង ជប៉ុន បាក់ស្រ៊ុបនៅឥណ្ឌូចិន ចក្រពត្តិអាមេរិចមេឈ្មួញ ឈ្មោភសង្គ្រាម បានប្រើល្បិចប្លន់ប្រទេស ចូលមកដើរតួជំនួសពួកអាណានិគមបារាំងដើម្បីជិះជាន់ ពលករនៅឥណ្ឌូចិន ។ មហិច្ឆតាដ៏ខ្មៅងងឹតរបស់ចោរចក្រពត្តិ ត្រូវបានអ្នកនិពន្ធចាប់អារម្មណ៍យ៉ាង ខ្លាំងក្លា ហើយក៏បានលើកយកមកលាត្រដាង បកអាក្រាតជូនសាធារណជនបានជ្រួតជ្រាបពី អាណានិគមបែបថ្មីនេះ ។

រឿងគូលីកំនែន បានបោះជំហានចូលយ៉ាងជ្រៅក្នុងចលនាតស៊ូរំដោះជាតិ ។ គឺជារឿងដែល បានទទួលឥទ្ធិពលពីចរន្តលទ្ធិសង្គមនិយម ព្រោះបានបំផុសកំហឹងប្រជាជាតិ អោយប្រជាជន ក្រោកឈរវាយរំលំចោរចក្រពត្តិ ប្លន់ទឹកដី ប្លន់សេរីភាព ចេញពីមាតុភូមិខ្លួនទៀត ក្រោយពីផ្ចាញ់ ពួកបារាំង ជប៉ុន អោយបាក់ស្បាតរួចមក ។ អ្នកនិពន្ធបានគូសបញ្ជាក់ថា ឯករាជ្យជាតិនិងសិទ្ធសេរី ភាពរបស់ម្ចាស់ស្រុកនឹងមានរស្មីភ្លឺត្រចះត្រចង់ទៅបាន លុះត្រាតែពួកចក្រពត្តិ ឈ្មួញសង្គ្រាម វិនាសសាបសូន្យផុតពីទឹកដីរបស់យើង ។ ទន្ទឹមនឹងនោះអ្នកនិពន្ធបានលើកបង្ហាញផងដែរ នូវ ស្មារតីស្នេហាសន្តិភាព ស្នេហាមនុស្សជាតិ ឈរលើសហប្រតិបត្តិការជាសន្តិសហវិជ្ជមាន រវាង ប្រជាជនទាំងអស់លើសាកលោក ហើយកត្តាដែលធ្វើអោយសំរេចបាននូវជ័យជំនះគឺចំនងមិត្តភាព

និង យុទ្ធសាមគ្គីភាពរវាងប្រជាជនចិនៈ កម្ពុជា វៀតណាម ឡាវ ។

យើងអាចសន្និដ្ឋានថា រឿងគូលីកំនែន ជារឿងមានលក្ខណៈតថនិយមជឿនលឿនខ្លាំងមែនទែន ដោយបានរិះគន់គ្រប់ស្ថាប័នគ្រប់គ្រងនាសម័យនោះ ។ ថ្វីត្បិតតែដំនើររឿងត្រូវបានអ្នកនិពន្ធប្រើល្បិចវាយស្របនឹងរដ្ឋអំនាចពេលនោះក៏ដោយ ក៏ការរិះគន់របស់អ្នកនិពន្ធមិនមានថមថយថាមពលដែរ គឺនៅមានសំទុះខ្លាំងក្លា ជំរុញចលនារំដោះជាតិយ៉ាងសកម្ម ។ ប៉ុន្តែយើងនៅមិនទាន់ចាត់ទុករឿងនេះជាប្រភេទរឿង តថនិយមសង្គមនិយមទេ ព្រោះបើតាមគំនរយៈកាលរីកចំរើននៃប្រវត្តិសាស្ត្ររឿងនេះអាចបំផុសបានត្រឹមតែ ធ្វើបដិវត្តន៍ប្រជាជន មិនទាន់ឈានដល់ធ្វើបដិវត្តន៍ប្រជាធិបតេយ្យនៅឡើយទេ ។

គណៈកម្មការ សុំកែសំរួល អក្ខរាវិរុទ្ធ តាមសំនេរបច្ចុប្បន្ន ឯឃ្លា ល្បះរក្សាទុកដដែល ។

គណៈកម្មការយើងខ្ញុំ សង្ឃឹមយ៉ាងមាំលើមិត្តអ្នកអាន ហើយរង់ចាំទទួលយោបល់រិះគន់ស្ថាបនាដោយសោមនស្សរីករាយ ។

ភ្នំពេញ, *ថ្ងៃទី ៣០ តុលា ១៩៨៣*

គណៈកម្មការអក្សរសិល្ប៍ និង ភាសា

# អារម្ភកថា

"គូលីកំនៃន" បានរៀបរៀងមុន "ស៊ឹមអ្នកបរឡាន" ។

យើងបានទាំងដកស្រង់ចំពូកខ្លះនៃរឿងនេះចុះក្នុងកាសែត " វត្តភ្នំ " ក្រោមខ្ទង់ " ស្ថានភាពស្រុកស្រែចំការ "មានរឿង "មេឃុំផា" និង " អោយមួយសេនទារមួយកាក់ " ជាដើម ។

ចំពោះរឿងនេះ យើងមិនធ្វើអត្ថាធិប្បាយខ្លួនយើងទេ យើងសូមគោរពអញ្ជើញបងប្អូនមើលកំសាន្តពិចារណា...។

អតីតចាងហ្វាងកាសែត "វត្តភ្នំ"

អ៊ឹម ថុក

*សីហា ឆ្នាំ ១៩៥៦*

# សេចក្តីប្រារព្ធ

សៀវភៅប្រលោមលោក " គូលីកំនែន " ដែលបានបោះផ្សាយពីលើកនៅប្រទេសខ្មែរ បានទទួលការគាប់ចិត្តអំពីសំនាក់អ្នកអានជាច្រើន ។

ដើម្បីជាប្រយោជន៍សិក្សាអក្សរសាស្ត្រជាតិរបស់យើង និងដើម្បីជាជំនួយក្នុងការយល់ដឹងមួយចំនែកណាអំពីជីវភាពរបស់ប្រជាជនខ្មែរ យើងខ្ញុំបានបោះផ្សាយសៀវភៅនេះក្នុងចំនោមមិត្តយើងដោយគោរពទៀងទាត់តាមច្បាប់ដើម ។

អញ្ជើញមិត្តយើងខិតខំពិចារណា និងអានជាកំសាន្ត ។

កញ្ញា ឆ្នាំ ១៩៦១

សាលាវប្បធម៌

# ១ មេឃុំផាន់

... ឆ្នាំ ១៩៣៥ ។ នៅឃុំគោកចំបក់ក្នុងស្រុកស្ទឹងកណ្តាលខាងត្បូងក្រុងភ្នំពេញរាជការបានហូតងារតាមេឃុំកឹម ហើយបានលើកពូផាន់អោយធ្វើមេឃុំជំនួសវិញ ។ ព្រឹត្តិការណ៍នេះបានធ្វើអោយអ្នកខ្លះព្រួយ អោយអ្នកខ្លះត្រេកអរ ។ អ្នកព្រួយបានដល់តាកឹម និងក្រមការចាស់របស់គាត់។ អ្នកសប្បាយលោតកញ្ឆែងវាយឌីទិនបានដល់ពូផាន់និងក្រមការថ្មីគាត់ ។ ប្រជាជនចំនួនច្រើនសំខាន់អ្នកនៅភូមិដើមអំពិលមិនបានខ្វាយខ្វល់នឹងការផ្លាស់មេឃុំទេ ។ គេច្រើនអោយយោបល់ថា៖ " អាគកដូចអាថៃ " ។ ថ្មីដូចចាស់ ។ ផាន់មិនខុសពីកឹមទេ។សុទ្ធតែពូកដៃជើងបារាំងទាំងអស់។ សុទ្ធតែពូកកំហែងចាប់ចង់ប្រជាជនដូចគ្នា....។ ហើយគិតតែគៃរកក្បាលកាក់ដូចគ្នា ។ យើងមិនឆ្លួតទៅកាន់ជើងអ្នកណាឡើយ ។

ពូផាន់មានស្របុកទ្រយុកច្រើនគ្រាន់បើក្នុងឃុំគោកចំបក់។ គាត់មានស្រែជាង ១០ ហិចតា។ តែស្រែគាត់មិននៅផ្តុំគ្នាជាបន្ទាត់ជាវាលទេ ។ គាត់មានត្រង់នេះស្រែថ្លុកពីរ ត្រង់នោះស្រែត្រពាំងបី ។ ល ។ សំបុកទ្រយុកស្រែច្រើនផ្សំនឹងអាកប្បកិរិយាស្គាល់លោកធំខ្លះបានត្រូវរាជការជំនាន់នោះរើសគាត់អោយធ្វើមេឃុំជួសតាកឹម ។ ពូផាន់មិនជិះសេះ មិនស្លៀកសំពាត់ផាមួងពាក់អាវកត្រង់ឡេវច្រើនដូចតាកឹមទេ ។ គាត់ច្រើនស្លៀកខោឡាញ់ខ្មៅពាក់អាវកុតសឡេវបី ប្រលាក់ក្អែល ញើសហើយពាក់ស្បែកជើងសង្រែក ។ សំលៀកបំពាក់គាត់ប្រាប់អ្នកផងទាំងពួងថា គាត់ជាអ្នកសម័យថ្មីមួយពាក់កណ្តាលក្រុង ពាក់កណ្តាលស្រែ ។

តាំងពីបានឡើងធ្វើមេឃុំមក ពូផាន់ខ្នះខ្នែងយកចិត្តទុក ដាក់ធ្វើការ ។ គ្រប់ចៅហ្វានាយបានសសើរគាត់ ហើយធ្វើបានតែ ៥ ឆ្នាំ គាត់បានរង្វាន់មេដាយពីរ ។ ពូផាន់បានដើរចូលគ្រប់ភូមិឆ្កឹះឆ្កៀលគំរាមកំហែងភូមិតូចតាចក្រីក្រ ។ ភូមិដើមអំពិលបានទទួលគាត់ស្ទើររាល់ខែ ។ ពូផាន់បានទុករៀងក្រៀមក្រំ ជាច្រើននៅភូមិនេះ ។

ម្តងគាត់បានមកភូមិដើមអំពិល មករកទារពន្ធថ្លៃខ្លួន ។ ពេលគាត់មក ឆ្កែព្រុះពេញភូមិ ។ អ្នកភូមិបានខ្សិបប្រាប់គ្នាថាមេឃុំមក ។ ស្រី ៗ និងចាស់ ៗ បាននៅអង្គុយធ្វើការក្នុងផ្ទះរៀងខ្លួន ។ ឯចំនែកអ្នកមិនទាន់បង់កាត ហើយនិងក្មេងជំទង់ ៗ អាយុ ១៦ ១៧ ឆ្នាំ បានគេចទៅវាលស្រែ រឺ

គេចទៅចំការជើងអស់ ។ ពេលនោះពូផាន់ឡើងមុខក្រហម ដោយរកមនុស្សមិនទាន់បង់កាតមិនជួប ។ គាត់លាត់អង្គុញជើងខោឡាញ់គាត់បែបជាមនុស្សស្រវឹងស្រា ហើយឡូឡាជេរបន្ទោសរ៉ូងរ៉ាំងនៅមុខផ្ទះក្រោមដើមអំពិលអាច់ឆ្មារខាងជើងភូមិថា ៖ " អាអិនខូចមែន " ។ តែឯងមក វាគេចបាត់ ។ ផ្ដាំប្រាប់វាថា តែដាច់ខែនេះមិនយកលុយទៅបង់ ប៉ូសីលសាលាស្រុកមកដាក់ខ្នោះហើយឯអាណាជំទង់ ៗ ក៏ល្មមកាន់ឡេសេហើយដែរ...។

... នៅថ្ងៃអាទិត្យ មួយរសៀល ពូផាន់បានជូនលោកចៅហ្វាពីភូមិដើមក្រសាំងចូលកាត់ភូមិដើមអំពិល ។ ពូផាន់ដើរសំដៅយ៉ាងលឿនទៅផ្ទះអាចារ្យគីម ។ គាត់ស្រែកបង្គាប់អាចារ្យគីមថា ៖ " បងអាចារ្យរកដូងបាន ៥ ជូនតេជគុណ និងចីដោយ ។ បងរកអោយឆាប់ព្រោះល្ងាចណាស់ហើយតេជគុណនឹងអាលទៅសាលាស្រុកវិញ ។ អាចារ្យគីមបានប្រញាប់ប្រញាល់រកបេះដូង ។ ឯអ្នកភូមិដែលបានបង់ពន្ធរួច បានបបួលគ្នាអង្គុយចោងហោងជុំវិញគ្រែលោចៅហ្វា ។ ពូផាន់ឆ្លៀតឱកាសនិយាយពន្យល់អ្នកភូមិថា៖ "ត្រូវប្រាប់គ្នាយកលុយមកបង់ពន្ធអោយបានឆាប់ភូមិដើមអំពិលនេះរឹងរូសជាងគេ មិនដូចភូមិឯទៀតទេ... ។ សាលាខេត្តបង្ខំអោយទារបានចុងខែនេះ ឃើញទេតេជគុណមកទូរណោរទាំងថ្ងៃអាទិត្យ ។

លោកចៅហ្វាបានជួយបន្ថែមថា៖ " រាស្ត្រមានភារៈតែមួយមុខគឺត្រូវបង់ពន្ធជូនរាជការ ។ គ្រប់ស្រុករាស្ត្របង់ពន្ធទាំងអស់ មានតែពួងក្រចេះស្ទឹងត្រែងដែលគ្មានកាត ។ ហេតុនេះត្រូវខ្ចីបុលគេឯងយកមកបង់ជូនរាជការអោយរហ័ស កំអោយប៉ូលីសចាប់ឃុំដាក់គុកទាន់" ។

ពិសាទឹកដូងរួច ពូផាន់បានជូនលោកចៅហ្វាទៅផ្សាបាត់ ។ អ្នកភូមិខ្លះដែលបានមកស្ដាប់បានខ្សឹបប្រាប់គ្នាថា " ផាន់ចេះផ្គាប់ចៅហ្វានាយមែន ។ អោយតែដល់ថ្ងៃអាទិត្យចុះ គាត់ទៅសកវាទ័ផ្ទះមីខ្វែន ភូមិដើមក្រសាំងភ្លាម ។ រួចគាត់ថាលោកចៅហ្វាយមកទូរណោរ " ។

ក្នុងពេលផាស៊ីសជប៉ុនចូលស្រុក ពូផាន់មានសកម្មភាពច្រើន ។ គាត់ហាត់នឿយញើសជាប់ដើរចូលទៅព័ទ្ធភូមិដើមអំពិល រកចាប់គូលីកំនែនអោយសឹកជប៉ុន ។ គាត់កាចសាហាវចាប់ពង្រាត់ប្ដីពីប្រពន្ធទាំងស្រស់ ៗ យកទៅពោធិចិនតុងអោយទ័ពជប៉ុន ។ ក្នុងរឿងកំនែននេះអ្នកភូមិដើមអំពិលបានខ្សឹបខ្សៀវប្រាប់គ្នាថា ៖ " មេឃុំផាន់ត្រូវក្ដោងហើយលើកនេះ ។ គាត់រកបានមួយលើកៗ តិចណាស់ក៏បងប្អូននឹងពាន់ដែរ " ។

....................................

# ២ យប់មួយនៃគ្រួសារតាង៉ែត

យប់ក្មេងដេកលក់ ។ ខាងក្រៅងងឹតចាក់ភ្នែកមិនធ្លុះ ។ ភូមិដើមអំពិលស្ងាត់ច្រៀប ។ ក្នុងផ្ទះល្វែងមុខ តាង៉ែត យាយម៉ុក នឹង លឹម ឪពុកម្ដាយកូនបីនាក់អង្គុយជុំកង់ជុំវិញ ចង្កៀងចានខ្លាញ់ត្រីមួយ ដែលមានពន្លឺបំភ្លឺភ្លឹមភ្លែត ។ ច្បាស់ប៉ុនចង្អេរ ។ នៅជុំវិញសសរទ្រូងមានផ្ដិលខាត់មួយ និងត្រលោកដូងពីរដាក់ទឹកពេញ ។ នៅបៀតយាយម៉ុកមានហឹងស្លារឈើមួយទ្រស្លឹកម្លូទុំលឿងលាយរលួយខ្មៅ ហើយនៅក្បែរនោះមានអកកំបោរធ្វើពីក្រលតាំងឆាយ ។ តាង៉ែតអង្គុយបៀតសំពៀតថ្នាំធ្វើអំពីស្លឹកត្នោត។ គាត់ឈ្ងោកស្ដោះទឹកមានជាញើក ហើយស្រមោលគាត់ផ្ដិតនៅជញ្ជាំងធំជាងរូបគាត់ប្រាំ ប្រាំមួយដងបានអន្ទោលឈ្ងោកចុះឡើងត្រាប់តាមប្រាណគាត់ ។ លឹមមុខក្រៀមស្រងូតកាន់កន្ទុយឈើតូចមួយឆ្កឹះប្រឆេះចង្កៀងចានខ្លាញ់ ។

តាង៉ែតយាយម៉ុកមានកូនប្រាំនាក់ ។ គាត់បានរៀបអោយមានផ្ទះសំបែង កូនច្បងបួននាក់រួចហើយ ។ នៅជាងមួយខែទៀត គាត់នឹងរៀបការកូនពៅលឹមគាត់ ។ ដល់រៀបការលឹមរួចគាត់នឹងចូលទៅរៀនវត្តត្បូង ។

អ្នកទាំងបីនាក់ជជែកគ្នា អំពីសុខទុក្ខក្នុងគ្រួសារ ។ យាយម៉ុក ពេលនេះត្រេកអររីករាយដោយដឹងថាកូនច្បងគាត់ពីរនាក់បានសុខសប្បាយ ។ តាង៉ែតសួរដំនឹងពីរក្មួនទីបី ដែលមិនបានមកលេងជិតពីខែ តាំពីប្រពន្ធឆ្លងទន្លេរួច ។ ក្រោយមក លឹមបាននិយាយ ៖ កំនែនលើកនេះ ពូផាន់កេណ្ឌអ្នកភូមិយើងដប់នាក់ ។ គាត់លេងអស់ដៃហើយ ។ គាត់ដឹងថាខ្ញុំរវល់រៀបការខែក្រោយគាត់ធ្វើបិទភ្នែក ហើយកេណ្ឌខ្ញុំយកទៅធ្វើគូលីជប៉ុនទាល់តែបាន... ។

យាយម៉ុកបានកាត់ ៖

ម៉ែលីថាពីអាទិត្យមុន នាងហេងយកភួយគរទៅជូនលោកចៅហ្វាយ ថាគេសរសើរនាងហេងគ្រប់ៗគ្នាត្បាញស្អាត... ។ ថ្មី ៗ នេះទៀត ពីម្សិលមិញ ម៉ែលីគេថាមេឃុំផាន់បានចោលសំដីថាលោកចៅហ្វាយចង់បាននាងហេង... ។ ឪវា អន្ទិតលឹមឯងបានលឺរឿងនេះ... ។

កាលខ្ញុំទៅផ្គាប់ពូស្វាយរដូវចំរូតមុន ខ្ញុំបានស្ទាបចិត្តឪពុកក្មេក ម៉ែក្មេកឃើញថាគាត់ល្អពិត។ គាត់មិនចេះប្រកាន់ទេ ហើយចូលចិត្តអោយខ្ញុំនិយាយជាមួយនឹងគាត់អង្គុយលេងជាមួយនឹងគាត់។

ឯចំនែកនាងហេងវិញ បានបញ្ចេញសេចក្ដីស្នេហាស្មោះត្រង់មកលើខ្ញុំ ។ ហេងមិនខ្មាស់អៀនគេច មុខលបហែកជញ្ជាំងមើលទេ ។ យើងបាយជាមួយគ្នា យើងបានបណ្ដើរគ្នាទៅមើលទឹកស្រែវែង យើងបានរែកអាចគោយកទៅចាក់ស្រែថ្វាន់ យើងបានជួយជាន់អង្គរគ្នា ។ ហេងបាននិយាយប្រាប់ខ្ញុំថា មុននឹងបានជួបខ្ញុំ ច្រូតនៅស្រែរៀនមានអាចារ្យឆេងអោយគេទៅដណ្ដឹងគាត់ម្ដងដែរ ។ តែដោយអាចារ្យឆេងធ្វើឬកធំពេក ធ្វើការងារចុងដៃចុងជើង ហេងក៏មិនព្រមទទួលយក ។ ពេលដែលខ្ញុំទៅបំរើ ខ្ញុំបានជួបជជែកអាចារ្យឆេងញឹកពីធម៌អាថ៌ ។ តាមខ្ញុំស្ដាប់ចិត្តហេង ខ្ញុំហ៊ានទុកចិត្តថាទុកតែ[1]មានអ្វីមករាំងរាក់ហេងមិនចោលខ្ញុំឡើយ ។ ខ្ញុំថាលោកថៅហ្វាយ [2]ទោះជាធំជាងនឹងទៅទៀត ក៏មិនអាចផ្ដាចសេចក្ដីស្នេហាយើងដ៏បរិសុទ្ធបានឡើយ ។ ហេងប្រាកដជាស្លាប់រស់ជាមួយខ្ញុំ...។

ឪអរតែដូចមាត់ទៅ ។ ឯងដឹងទេពេលឥលូវមេឃុំផាន់មានអំនាចណាស់ ។ គេអាចខ្វារទោសពង្រាត់ប្រពន្ធកូនបានដោយងាយ ។ ឯងចាំទេ កាលកំនែនមុនដំបូងនោះផាន់បានបង្ខំចាប់អន្ទិតអិនយកទៅពោធិចិនតុងទាំងឈឺទាល់តែគ្នាស្លាប់នៅកន្លែងធ្វើការទៅ ។ ឥលូវនាង យិនអាសៅ ម្ដាយកូននៅរហេមរហាមជាពន់ពេក ហើយមិនបានទាំងឃើញផ្សែងភ្លើងប្ដី និង ឪផង ។ ឪបារម្ភណាស់ឯងទៅធ្វើគូលីកាលណា ?

កំនែនលើកនេះត្រូវទៅព្រឹកស្អែក...

អញតែនឹករឿងកំនែនអញក្ដៅណាស់ ។ មួយជីវិតអញនេះ ជាប់កំនែនស្ទើររាល់ឆ្នាំ ។ ថ្នល់ព្រែកហូរចាក់អង្រៃ សុទ្ធតែអញបានលើកទាំងអស់ ផ្សារសាលាស្រុក ក៏អញបានលើកបានឆាយដែរ... ។ អាបារាំង អាជប៉ុន នេះចំជាពូកចង្រៃគិតតែពីរកេណ្ឌពីចាប់ខ្មែរ... ។

កម្មរបស់យើងទេ! ឪវាអើយ (យាយម៉ុកបានឆ្លើយយ៉ាងស្ងួត) ។ យើងរាស្ត្រត្រូវតែទទួលកម្មនេះ ព្រោះយើងបានធ្វើបុណ្យពីជាតិមុនមិនល្អ... ។

គ្មានកម្មឯណាទេម៉ែ ។ (លឹមបានកាត់ ) ។ មកពីយើងល្ងង់ មកពីយើងខ្សោយបានជារាជការបារាំង ជប៉ុនអស់នោះសង្កត់យើង... ។

---

(១) សៀវភៅចាស់ដាក់ " គង់តែ " កែជា " ទុកតែ "

(២) សៀវភៅចាស់ដាក់ " គង់តែ " កែជា " ទោះជា "

នាម៉ឺនស្តេចជាពួកទេព្តាចុះមកយកកំនើតជានមនុស្សលោក អន្ទិតលឹមឯងដឹងទេ ។ ( យាយម៉ុកបានឆ្លើយ ) ។ យើងពីជាតិមុនមិនខំធ្វើបុណ្យ បានជាជាតិនេះត្រូវវេទនា... ។

កុំច្រលំម៉ែ ។ ( លឹមកាត់ ) ។ មនុស្សយើងកើតមកមានសិទ្ធិស្មើគ្នា គ្មាននរណាធំជាងនរណា... ។

ឈប់និយាយរឿងនេះទៅអន្ទិតលឹម ។ ( យាយម៉ុកបន្ទោស ) ។ ឯងលែងជឿបុណ្យបាបហើយ នែឪវា យើងបបួលគ្នាថ្វាយបង្គំព្រះទៅវិញល្អជាង ថាចប់ភ្លាមយាយម៉ុកក្រោកដើរទៅហូតធូបបីសសៃពីបំពង់ក្រដាសពណ៌លឿង ហើយអុជបូជាព្រះពុទ្ធរូបមួយកញ្ចក់ដែលបានចងព្យួរនៅជញ្ជាំងស្លឹកក្បាលដំនេក ។ លឹមមិនបាននៅរួមថ្វាយបង្គំជាមួយផងទេ ។ គាត់ចុះទៅដីដាក់ចំបើងមើលភ្លើងគោ តាង៉ែត យាយម៉ុក បានអង្គុយបត់ជើងបែរមុខទៅរកកញ្ចក់ពុទ្ធរូបសូត្រធម៌វត្តល្ងាចសន្យាប្រព្រឹត្តតាមទាំងអស់ ។ ដល់សូត្រចប់យាយម៉ុកបានបួងសួងដល់ទេព្តាអ្នកតាចាស់ស្រុកលោកយាយចាស់ស្រុកទាំងប៉ុន្មានដែលរក្សាភូមិដើមអំពិលអោយជួយកំចាត់ដេញសត្រូវ កុំអោយមកបៀតបៀន សូមអោយបានទឹកភ្លៀងគ្រប់គ្រាន់ កុំអោយមានក្តាមកណ្តុរចាបស៊ីស្រូវ ។

រាល់យប់រួចពីសូត្រធម៌វត្តល្ងាច តាយាយបានចូលដំនេកភ្លាម តែយប់នេះគាត់បានអង្គុយនៅបៀតចង្កៀងចានខ្លាញ់ ហើយនិយាយគ្នាទៅទៀត ។ តាង៉ែតបានផ្តើម ៖

អន្ទិតលឹមប្លែកណាស់ឥលូវ ។ វាខុសពីក្មេងឆ្ងាយណាស់ ។ កាលនៅពីកុមារវាជាអ្នកលេងច្រើន សប្បាយច្រើន ។ លោកគ្រូស្រលាញ់វា ហើយយកវាដើរតាមគ្រប់ខេត្តរហូតដល់សៀមដល់បាស័កព្រះត្រពាំង ។ វាចេះស្មូតចេះចេះធ្វើបទពាក្យ៧ ៨ កាកគតិ ភុជុង្គ ពំនោល ព្រហ្មគិតិ ។ល។ កាលនៅបួសវាដើរទេសនាយ៉ាងល្បីល្បាញចេះគម្ពីរគួរសមដែរ ។ តែតាំងពីសឹកមកវាប្រែច្រើន ឬក្រឹមត្រូវ តែវាមិនជឿការបន់ស្រន់ទៀតឡើយ ។

វាជាកូនចេះដឹងណាស់ ។ ( យាយម៉ុកបានឆ្លើយ ) ឪវាឃើញទេ ប៉ុន្មានថ្ងៃនេះវាបានជាន់អង្ករ រែកទឹកចាក់ពេញពាងទុកអោយយើងស្រេច ។ វាមិនដែលធ្វើអោយយើងព្រួយទេ ។ ស្រាមិនផឹក ដើរលេងយប់ក៏មិនដើរ... ។

អន្ទិតលឹម ! ម៉ែឯងឆ្ងល់ណាស់ ។ ឯងដែលចេះធម៌ទេសនាប្រដៅគេទៅរហូតដល់សៀមដល់បាស័កព្រះត្រពាំង បែរមកសឹកលែងជឿកម្មផលអស់ លែងបន់ស្រន់អស់... ។

ព្រោះតែខ្ញុំបានទៅបាស័កព្រះត្រពាំងហើយបានជាខ្ញុំកែប្រែ ។

ហេតុអ្វីក៏ដូចនោះ ?

ឪមិនដឹងទេ ។ កាលខ្ញុំបួសបានពីរវស្សា ខ្ញុំបានតាមលោកគ្រូទៅបាស័កព្រះត្រពាំង ។ នៅកុដិដែលខ្ញុំនៅរាល់ថ្ងៃសីល មានឧបាសកខើចជើងពិការម្នាក់ បានយកចង្ហាន់មកប្រគេនលោក ។ ឧបាសកនេះចូកចិត្តនិយាយ ពីរឿងសង្គមមនុស្សដែលកើតមានលើដីពិត ។ ។ គាត់ឆ្លាតវៃចេះបបួលលោកគ្រូអោយចូលចិត្តស្តាប់រឿងគាត់និយាយ ដូចជារបៀបគ្រប់គ្រងរដ្ឋក្នុងសាកលលោក ហើយនិងការប្រែប្រួលសង្គមក្នុងលោកតាំងពីកើតមនុស្សមក ។ ឧបាសកចំលែកពិការជើងនេះបានសូមអនុញ្ញាតលោកគ្រូមេកុដិបើកច្បាប់អោយភិក្ខុសាមណេរនៅក្នុងកុដិ មកជជែក មកស្តាប់លេង កាលណាគាត់មកនិយាយ ។ ដូចនេះវេលាគាត់មកម្តងៗ នេន ភិក្ខុ បានមកជុំអង្គុយបត់ជើងចាំស្តាប់គាត់ប្រាជ្ញ ។ ក្នុងសេចក្តីទេសនារបស់គាត់ៗ មិនដែលនិយាយពីរឿងប៉ះពាល់ដល់ពុទ្ធសាសនាទេ ។ គាត់និយាយតែការជាក់ស្តែងពិតៗ មានអ្នកស្តាប់ចំនួនច្រើន ទាំងសង្ឃ ទាំងគ្រហស្ថបានពិចារណានូវសំដីគាត់ហើយបានយល់ព្រមតាមគាត់ ។

ថ្ងៃមួយ គាត់បានលើកបញ្ហាមួយមកអោយលោកសង្ឃជួយពិចារណា ។ គាត់សូមអោយជួយរកហេតុភេទ រឹសកែវដែលធ្វើអោយប្រជាជនវៀតណាមវេទនាតោកយ៉ាល្វិតល្វង់ ។ មានលោកសង្ឃច្រើនអង្គបានមូលមាត់ថា ៖ ទុក្ខវេទនារបស់ប្រជាជនវៀតណាមកើតមកពីកម្មអាក្រក់ដែលខ្លួនបានធ្វើពីជាតិមុន ហេតុនេះជាតិនេះត្រូវទទួលកម្មផលរបស់របស់ខ្លួន ។ បើចង់ផុតទុក្ខវេទនាត្រូវតែខំកសាងស្មាទាន ស្វែងរកផ្លូវទៅនិព្វាន...។

ឧបាសកខើចជើងបានឆ្លើយតបឡើង តាមយោបល់ខ្ញុំព្រះករុណាខ្ញុំបាទ ទុក្ខវេទនារាស្ត្រវៀតណាម និងរាស្ត្រខ្មែរ គឺបណ្តាលមកពីរបៀបគ្រប់គ្រងរាជការនៅប្រទេសនោះ ។ មេរោគធំ ៗ ដែលធ្វើអោយប្រជារាស្ត្រខំធ្វើការមួយថ្ងៃ ៗ ពីព្រលឹមដល់ព្រលប់តោកយ៉ាកអត់បាយស្ទើររាល់ឆ្នាំ គឺមកពីការជិះជាន់នៃពួកបារាំង និងពួកអុងជ្រូ[១] ដែលចូលរួមគ្នាការពារផលប្រយោជន៍ផ្ទាល់ក្រុមគេ ។

ក្នុងពេលនោះ មានឧបាសកម្នាក់សក់ស្កូវចាស់បន្តិច ដែលជាម្ចាស់ដីមានរាប់រយហិចតា

---

១) ថៅកែ

ហើយមានគូលី ឈ្នួលដល់រយនាក់ បានឆ្លើយដោយគំរាំងថា ៖ " មានតែពួកកុងសាងកុំមុយនីសទេ ដែលអាចនិយាយដូចលោក " ។

ចំពោះសំដីម្ចាស់ដីនេះ ឧបាសកខើចជើងបានឆ្លើយដោយរមទមថា ៖

ខ្ញុំមិននិយាយពីកុងសាង កុំមុយនីស ពីហ្វាហារ ពីការវដាយទេ ។ ខ្ញុំគ្រាន់តែសូមយោបល់របស់អស់លោក និងព្រះតេជគុណគ្រប់អង្គតែប៉ុននោះ ។

ឧបាសកម្ចាស់ដីគ្មានឆ្លើយទៀត ហើយគ្រប់សង្ឃនៅស្ងៀម ។ ឧបាសកខើចជើងនិយាយរឿងផ្សេងទៀត ។ ខ្ញុំបានពេញចិត្តសេចក្ដីអធិប្បាយរបស់ឧបាសកនោះណាស់ ។ ខ្ញុំបានសាកសួររៀនពីឧបាសកនោះរំលាយការងឿងឆ្ងល់ជាច្រើន ។ ហើយក្នុងកំលុង ៦ ខែនៅកុដិសំនាក់នោះ ខ្ញុំបានស្ដាប់ បានចេះរឿងជាក់ស្ដែង ច្រើនលើសពីសាស្ត្រល្បែងសាស្ត្រទេសន៍ ។ ខ្ញុំបានកំនត់ទុកថាឧបាសកខើចជើងជាមនុស្សស្រលាញ់អ្នកក្រីក្រពិត ៗ ហើយប្រមូលរកគ្នាដោះទុក្ខអ្នកតោកយ៉ាក ។ ខ្ញុំបានសន្យាក្នុងចិត្តថា ដល់សឹកត្រលប់ ទៅជួបគាត់វិញ ។ តែដោយជាប់ចំនងគ្រួសារ ខ្ញុំក៏មិនបានត្រលប់ទៅជួបគ្នាវិញ ។ ការខ្វាយខ្វាល់ចិញ្ចឹមជីវិតដោយវេទនា សព្វថ្ងៃបានបង្ខំអោយខ្ញុំចៀសមិនផុតពីការចិញ្ចឹមសត្វ ពីការរកក្ដាម នេសាទត្រី ហើយធ្វើអោយឃ្លាតឆ្ងាយពីការបន់ស្រន់ជឿរទេវតាជឿអ្នកតា... ។

តាមម៉ែ បើវេទនាដូចនេះ គួរណាស់តែខំភាវនា ខំធ្វើបុណ្យថែមទៀត មិនត្រូវឡើយគិតតែរកត្រី ចិញ្ចឹមមាន់ ។

ខ្ញុំយល់ថា ៖ ក្ដីវេទនាយើងនេះ មិនមែនមកពីកម្មផលវាសនាទេ គឺប្រាកដមកពីរបបបារាំងជប៉ុនជិះជាន់ ។ បើចង់សុខទាល់តែយើងខំប្រឹង មិនមែនគ្រាន់តែយើងអុជធូបអង្វរទេព្ដា បានសុខទេ ។

ឈប់និយាយទៅ ។ ( តាង៉ែតបានឃាត់ ) ។ អន្ទិតវាមិនស្ដាប់យើងទេ ។ តាមយថាកម្មវាចុះ...។

លត់ចង្កៀងទៅ ។ ស្អែកព្រឹកឯងដើរទៅពោធិចិនតុងផង ។ ( យាយម៉ុកបានបន្ថែម ) ។

ថាចប់យាយតាចូលដំនេក ។ លឹមបិទទ្វារ លត់ចង្កៀងរួចហើយ គាត់បានប្រះដេកលើកន្ទេលក្រហមនៅខាងជើងមាត់ទ្វារ...។

....................................

# ៣ ប្រមូលកំនែន

មាន់រងាវលើកទីពីរ យាយម៉ុកភ្ញាក់ក្រោកឡើង គាត់បង្កាត់ភ្លើងដាំបាយដុតប្រហុកខ្ចប់ត្រីងៀត អំបិល បុកក្រសាំង អំពិលរៀបចំអង្ករអោយកូនពៅគាត់ ថ្ងៃរះចោលកម្មរស្មីក្រហមឆ្អៅបពីទិសខាងកើត តាង៉ែតបានក្រោកដើរថ្មមៗ មិនអោយរង្គើរនាប ។ ចុះដល់ដីគាត់និយាយតិច ៗ ជាមួយប្រពន្ធគាត់ថា ៖

យើងស្ដីបន្ទោសអន្ទិតខ្លាំងពេក យប់មិញបានជាវាដេកក្រលក់ ។ អញ លីតែវាប្រែប្រួលចុះឡើងហើយដកដង្ហើមធំជាញឹក... ។ អញមិនដាស់វាទេ អញចង់ទៅធ្វើគូលីជួសវាបើវាសុខចិត្ត...!

កុំដាស់វាអី ឪវាអើយ ! ទុកអោយវាដេកសិនចុះ គង់តែអន្ទិតថនមកហៅវាទេ...។ ថ្ងៃរះកំពស់ចុងឈើអ្នកភូមិបានចេញទៅធ្វើការគ្រប់គ្នា ។ ក្មេង ៗ រត់លេងមីនៅក្រោមដើមអំពិលអាចម៍ឆ្មាមុខភូមិ ។ អន្ទិតថនបានមកហៅលឹម ។ លឹមដឹងខ្លួនក្រោកឡើងស្ទុះទៅដី ខ្ពុរមាត់លាងមុខ ប្រញាប់ប្រញាល់ពុនអង្ករមួយកូនការុងនិងកញ្ចប់បាយប្រហុកដាក់ក្នុងបង្គី។គាត់លាម៉ែឪគាត់។ យាយម៉ុកបានស្រែកផ្តាំថា ៖

ត្រីឆ្អើរនៅក្នុងការុងអង្ករជារបស់នាងហោង ដេលយកមកអោយឯងពេលស្រាង ១ នេះ...។ នាងហោងមិនបាននៅជូនដំនើរឯងទេ...។ នាងហួសទៅដកថ្នាលខ្ទម្ព មីស្រមូនបាត់ហើយ...។ ឯងទៅធ្វើការជាមួយគេប្រយ័ត្នកុំមាត់ផ្តេសផ្តាស...។

លឹម និង ថនបានដើរកាត់ភូមិទៅត្បូង ។ ដល់ចុងភូមិគាត់ចូលទៅហៅតាមុយរួចអ្នកទាំងបីបានបណ្តើរគ្នាសំដៅទៅផ្ទះមេឃុំផាន់នៅភូមិគោកចំបក់ ។ តាមុយបានផ្តើមសួរលឹមថា ៖

ឯងដឹងទេ ?

រឿងអ្វី ?

រឿងកំនែន ។ ឆ្នាំនេះរាជការបង្គាប់កេណ្ឌគូលី ១០០ នាក់មួយលើក ១ ក្នុងមួយឃុំហើយបើនរណារឹងទទឹងនឹងបង្គាប់នេះ មេឃុំមានអំនាចចាប់ដាក់ខ្នោះបញ្ជូនទៅសាលាស្រុក ទៅសាលខេត្ត។ ផាន់បានចាត់ក្រុមប៉ូលីសអោយកេណ្ឌលើសម្តែនាក់សំដៅទៅលើគ្រួសារណាដែលមានធុរៈ

ធ្ងន់ ហើយបើគង់យកទៅបាញ់ចោល ក៏អ្នកម្ដែនាក់នោះឃ្លាតពីផ្ទះមិនបានដែរ ។ ចំពោះអ្នកម្ដែនាក់ផាន់ប្រើឧបាយកល ធ្វើជាចិត្តល្អបន្ធូរបន្ថយមិនប្រិតខ្លាំងពេកទេ ។ គាត់ធ្វើជាយោកយល់ដោយមានធុរៈធ្ងន់ ។ ជាន់បង្ខំអោយអ្នកម្ដែអ្នកនោះបង់ប្រាក់វិញ ។ គាត់ធានារកជួលគូលីជួសយកតំលៃឈ្នួលម្នាក់ ៥០ រៀល ។

មេឃុំផាន់ ធ្វើជាបន្ធូរខ្លាំងទៅដល់អ្នកក្រវេទនា ។ គាត់មិនយកប្រាក់ឈ្នួលភ្លាមទេ គាត់ធ្វើជាចេញប្រាក់ផ្ទាល់ខ្លួនគាត់ជួសមុនសិន ។ ដូចនេះមេឃុំផាន់ក្នុងកំនែនមួយលើក ៗ បានធនធានបានអំនាចបានក្ដីដឹងគុណខ្លះពីអ្នកក្រវេទនា ។ មេឃុំផាន់កត់ជាជំពាក់គាត់ ដល់ខែភ្ជួររាស់ រឺខែច្រូតកាត់ទោទារសំនងពីអ្នកក្រីក្រជំពាក់គាត់ទាំងនោះអោយមកភ្ជួររាស់ដកស្ទូង ច្រូតអោយគាត់ ។ ធម្មតាប្រាក់បានមកដោយវិធីនេះ ផាន់ចែកទៅអោយភ្នាក់ងារគាត់ខ្លះ ទុកខ្លួនគាត់ខ្លះ ទិញអីវ៉ាន់ជូនលោកប្រុសលោកស្រីខ្លះ...។

គ្រប់តែមេឃុំប្រព្រឹត្តដូចជាន់ទាំងអស់រឺ ? ( លឹមបានសួរបញ្ជាក់ )

មានតិចណាស់ដែលត្រឹមត្រូវនោះ ។ ១០០ នាក់មានមិនដល់មួយផង...។

លឹម និងតាមុយ បានជជែកគ្នាពីនេះពីនោះចប់តាមផ្លូវដើរកាត់ទួលគោកត្រស់ រួចក៏បានទៅដល់ភូមិគោកចំបក់ ។ នោមុខផ្ទះមេឃុំផាន់ កំនែនបានមកដល់បន្ដ១គ្នា ។ គ្រប់ចំនួន ១០០ នាក់ មេឃុំផាន់មានប៉ូលីសពីរនាក់ស្ពាយកាំភ្លើង បានបណ្ដើរកំនែនទៅសាលាស្រុក ។ ថ្ងៃជិតត្រង់ហ្វូងគូលីកំនែនឃុំគោកចំបក់ បានទៅដល់សាលាស្រុកដែលថ្ងៃនេះធ្វើរហូតគ្មានឈប់សំរាក ។ ក្នុងវាលរបងមុខសាលាស្រុក គេឃើញមានកំនែនឃុំងទៀតបានមកដល់មុនខ្លះ អង្គុយជាសង្កាត់តាមឃុំក្បាលមីរនៅផ្ទាល់ដី ។ កំនែនគ្រប់គ្នាតោយ៉ាកស្លៀកខោស្នាប់ភ្លៅលើជង្គង់បំនះយុល មុខក្រៀមអង្គុយអោយគេរាប់ក្បាល់ដូចជាមានទោសប្លន់ រឺ ទោសលួច ។

លោកបាល័ដ្ឋសស្អាតទំនងជាកូនកាត់ចិនខ្មែរអាយុប្រហែ ២៥ ឆ្នាំ និងថីដោយប៉ូលីសមួយរូបទៀតបានកាន់សំភារៈទទួលកំនែន ។ ថ្ងៃទទួលកំនែននេះ លោកបាល័ដ្ឋបានរៀបតុនៅរានហាល ។ គាត់អង្គុយក្រោយតុហើយនៅខាងស្ដាំតុ ថីដោយបានឈរប្រេបជួយមើលការខុសត្រូវ ។ មេឃុំមួយម្ដង ១ បានដើរឡើងទៅតុលោកបាល័ដ្ឋ ហុចបញ្ជីដៃពីររួចសំពះលាចុះមកវិញ ។

ពូមេឃុំផាន់មិននៅស្ងៀមទេ គាត់រៀបចំបញ្ជីគាត់ហើយចាំផ្ទៀងស្ដាប់លោកបាល័ដ្ឋហៅ ។

មិនយូរប៉ុន្មានគេលឺ ៖

អាគោកចំបក់នៅឯណា ? បានគូលីគ្រប់ចំនួនទេ ? ពូផាន់ភ័យញ័រកាន់បញ្ជីទៅជូនលោកបាល័ដ្ឋ ឆ្លើយសំពះលើកដៃពីថា ៖

ទានប្រោសរកគ្រប់ចំនួនហើយ !

គ្រាន់បើល្អ ឃើញទេអាកញ្ចះស្វាយ ហេតុអ្វីក៏តាប៉ិងឯងមិនខំកេណ្ឌអោយដូចអាគោកចំបក់ ។ ប្រយ័ត្នហូតងារចោល ( លោកបាល័ដ្ឋបានបន្ទោសមេឃុំ ៗ ស្វាយ ) ។ ពូផាន់បានសំពះលោកបាល័ដ្ឋដើរថយក្រោយមកវិញ ហើយមុខគាត់បានស្រស់ ។ ឃើញដូចនោះលឹមលាន់មាត់សួរតាមុយថា ៖

យីពូផាន់បានជាមួយតែអ្នកតូចទេ ! នៅមុខលោកបាល័ដ្ឋមុខកញ្ជ្រោនដូចឈើពោះឯចឹង..។ ហើយលោកបាល័ដ្ឋបែបកាចណាស់ ហៅតាមេឃុំ ៗ ស្វាយសុទ្ធអាកញ្ចាស់... ។

ជាការធម្មតាទេចៅអើយ ! អ្នកធំត្រូវតែកាន់ឬកដូចនេះ ហើយអ្នកតូចត្រូវតែសំពះត្រូវតែលូន...។

មិនមែនធម្មតាទេ ! ( លឹមប្រកែក ) ។ តាមខ្ញុំដឹងថា មានតែក្នុងស្រុកខ្ញុំគេទេដែលនាម៉ឺនជិះជាន់រាស្ត្រ នៅប្រទេសប្រជាធិបតេយ្យ ប្រជារាស្ត្រមិនថោកដូចស្រុកយើងទេ...។ រាស្ត្រគេមានសិទ្ធមានសេរីភាពជជែកតវ៉ាបាន ហើយថារបបលុតក្រាបដើរទាក៏មិនសូវមានដែរ...។

... តាមិនសូវដឹងទេរឿងនេះ ។ ឯងកុំនិយាយខ្លាំងពេក តិចមេឃុំផាន់លឺ...។ និយាយអ្វី ៗ ត្រូវងាកមើលឆ្វេងស្តាំ...ប្រយ័ត្ន...។ ( តាមុយបានទូន្មាន ) ។

លុះទទួលបញ្ជី និងប្រមូលគូលីបានគ្រប់ចំនួនដូចជប៉ុនបង្គាប់ លោកបាល័ដ្ឋ ចឺដោយនិងប៉ូលីសប្រាំនាក់ទៀតស្ពាយកាំភ្លើង បានបណ្តើរគូលីកំនៃនមានប្រហែលជានពាន់នាក់ទៅពោធិចិនតុង ។ ថ្ងៃជ្រេជិតលិចកំនៃនបានទៅដល់កន្លែងធ្វើការ ។ សក្តិពីរជប៉ុននៅកាន់កាប់ត្រួតកន្លែងនោះបានចាប់ដៃទះស្មាអង្អែលខ្នងលោកបាល័ដ្ឋយ៉ាងរាក់ទាក់ សរសើរពូកែកេណ្ឌគូលី ជួយទ័ពជប៉ុន ហើយសន្យាអោយប្រលង់ដៃសរសេរជាអក្សរជប៉ុន បើកច្បាប់អោយលោកបាល័ដ្ឋចេញចូលពោធិចិនតុងមើលយន្តហោះឡើងចុះបានតាមចិត្ត ។ លោកបាល័ដ្ឋរករាយហើយធានាថា ថ្ងៃ

ក្រោយកេណ្ឌអោយច្រើនជាងនេះទៅទៀតបើជប៉ុនត្រូវការស្លឹកត្នោតប្រាប់សាលាស្រុក ៗ រកជូនបានទាំងអស់ ។ ប្រគល់បញ្ជីនិងគូលីរួចកាលណាលោកបាល័ដ្ឋបានគំនាប់ចាប់ដៃសក្តិពីរជប៉ុនត្រលប់ទៅវិញ ។

ឯចំនែកគូលីកំនៃន ទាហានជប៉ុនបានឃុំនៅក្នុងបន្ទាយរបេងលូសបន្លាអោយជីកដីធ្វើផ្លូវយន្តហោះដឹកថ្ម ដើម្បីមូលដ្ឋានសង្គ្រាមផាស៊ីសមហាអាស៊ី... ។

........................................

# ៤ ម្ដូរផ្កាច់ដូចទាវនិងឯក

លឹមទៅពោធិចិនតុងបានដប់ថ្ងៃ ព្រឹត្តិការណ៍ច្រើនចំលែកបានកើតឡើងរវាងគ្រួសារនាងហេងនឹងមេឃុំផាន់ ។ អ្នកភូមិដើមអំពិលបានយកចិត្តទុកដាក់គ្រប់គ្នាពីរឿងនេះ ។ គ្រួសារនាងហេងដែលបានទទួលគ្រោះថ្នាក់ផ្ទាល់បានប្រជុំគ្នា ។ ពូស្វាយបានប្រមូលប្រពន្ធនិងកូនស្រីគាត់ មកសួរដណ្ដឹងរកផ្លូវដោះស្រាយ ៖

ក្រហេង មេឃុំផាន់មកពីអាទិត្យមុននិយាយអ្វីខ្លះ ?

គាត់បានមកបញ្ចោរគ្រួសារយើង ។ គាត់ថាខ្ញុំមុខស្រស់រាងសមម្រាមដៃដូចបន្លាក្រូចកំភួនជើងតូចល្អ មិនគួរឡើយនៅធ្វើស្រែទេ ។ រូបរាងខ្ញុំសមជាអ្នកក្រុងធ្វើយុនអ្នកម្នាង ធ្វើលោកជំទាវលោកស្រី បើមិនដល់ប្រពន្ធទីមួយហោចណាស់ក៏បានធ្វើប្រពន្ធទី ៣ រឺ ស្រីលោកចៅហ្វាយដែរ ។ គាត់ថាលោកចៅហ្វាស្រលាញ់ខ្ញុំ សរសើរភ្ញយគរដែលខ្ញុំត្រូវកេណ្ឌត្បាញជូនលោក ថាលលោកសំពន្ធមិនលក់ បាយមិនឆ្ងាញ់ ហើយចង់លែងប្រពន្ធលោកទាំងពីរ ហើយដេកយប់ថ្ងៃស្រមៃឃើញខ្ញុំ នៅនែបនិត្យនិងលោកជានិច្ច ។ គាត់ថាគួរណាស់តែខ្ញុំជួយជីវិតលោកចៅហ្វាយផង ។ រួចពីសរសើរគ្រប់គាត់បានហុចកញ្ចប់ម្សៅនិងទឹកអប់ សាប៊ូក្រអូប សំពត់ព្រៃបីម៉ែត្រ ព្រមទាំងផ្លែក្រូចម្ចាស់នំចិនមួយកញ្ចប់ផង ហើយថាជាជំនូនលោកចៅហ្វាផ្ញើមកជូន ។

ក្រហេងឯងបានប្រាប់គាត់ដូចម្ដេចវិញ ? ( ពូស្វាយបានបញ្ជាក់ ) ។

ខ្ញុំជំរាបគាត់ថា ខ្ញុំជិតការហើយ ។ សូមកុំអោយមករវីរវល់ទៀត ខ្ញុំបានបង្វិលប្រដាប់ប្រដាទៅគាត់ទាំងអស់ ។ តែពីព្រឹកមិញនេះគាត់មកទៀត មានប៉ូលីសពីរនាក់មកផង ។ គាត់កំហែងចង់ចាប់ខ្ញុំ ។ ខ្ញុំបានអង្វរគាត់ថាកុំអាលប្រញាប់ពេក...។ គាត់បានប្រាប់ខ្ញុំថា លើកទីបីគាត់លេងមែនទែនហើយ...។

រឿងក្រហេងនេះពីបាកណាស់ តើម៉ែវាគិតដូចម្ដេច ? មីងពតគិតមួយស្របក់ឆ្លើយ ៖

ពីម្សិលមិញ យាយចាន់ភូមិត្បូងបានជួបអញ ។ គាត់បានអោយយោបល់ថាយើងមានសំនាងគួរណាស់តែផ្ដាច់ពីអន្ទិតលឹម ហើយលើកក្រហេងអោយទៅលោកចៅហ្វាយ ។ គាត់ថាបើ

កូនគាត់វិញ គាត់ជូនលោកថៅហ្វាយស្រេច មិនអោយវាទៅកាយដី ត្រាំភក់ដល់ណាទេ ។

ម៉ែវាឯងយល់ស្របតាមយាយចាន់ រឺ ?

ចំនែកអញគ្មានយោបល់ទេ ។ បើក្រហេងវាចង់នៅកាយដី នៅជាមួយអន្ទិតលឹមទៅបើចង់បានស្រនុកមានសំពត់មាសពេជ្រពាក់នឹងគេ ទៅនៅជាមួយថៅហ្វាយទៅ ។ មេឃុំផាន់គេសុខចិត្តសងបណ្ណាការទៅតាង៉ែតវិញ...។

ចំនែកអញមិនយល់ស្របតាមឯងទេ ។ អញអ្នកស្រែមិនចង់អោយកូចថៅទៅនាម៉ឺនទេ ។ ឯងមិនលឺក្រហេងប្រាប់ទេថា លោកថៅហ្វាយមានប្រពន្ធពីររួចទៅហើយ ហើយនៅមានកៀនកោះទៀតតាមអញដឹងមីខ្វែនភូមិក្រសាំងនេះ ក៏ស្រីមេឃុំផាន់នាំអោយលោកដែរ។ ណ្ហើយមុននឹងសំរេចអញចង់ដឹងក្រហេងសិនតើឯងគិតដូចម្ដេច ?

យើងបានទទួលជំនួន និងពាក្យតាង៉ែតរួចហើយ ៗ នៅជាងមួយខែទៀតយើងនិងរៀបការ ។ បងលឹមបានទាំងមកនៅផ្ទះយើងកាលចំរូតអស់មួយខែ ។ ខ្ញុំបានស្គាល់ចិត្តគាត់ ឃើញថាគាត់អាចជាទីជំរករបស់ខ្ញុំបាន ។ យើងប្រាកដជានៅជាមួយគ្នាយ៉ាងសុខ កុំថាលោកថៅហ្វាយគង់តែកុងសីក៏ខ្ញុំមិនអាចបែកចិត្តពីបងលឹមបានឡើយ ។ ឪមិនចាំទេយប់មួយបងលឹមបានខ្ចីសាស្ត្រាទាវ ឯករវត្តត្បូងយកមកមើល ។ ព្រឹកឡើងខ្ញុំនិងគាត់ជាន់អង្ករពីរនាក់ ខ្ញុំបានប្រាប់គាត់ពីដំនើរអាចារ្យឆេង ហើយគាត់បានពន្យល់ខ្ញុំអំពីសេចក្ដី ស្នេហា ស៊ូស្លាប់រវាងទាវនឹងឯក ។ ខ្ញុំបានសន្យាថា ខ្ញុំសុខចិត្តប្ដូរផ្ដាច់រស់នៅជាមួយគាត់ ដូចទាវបានប្ដូរផ្ដាច់ជាមួយនឹងឯក ប្រកែកមិនព្រមធ្វើស្នំមហេសីព្រះរាមា ។

អញក៏ពេញចិត្តលឹមណាស់ដែរ ។ ( ពូស្វាយបានកាត់ ) អន្ទឹតលឹមត្រឹមត្រូវស្រឡាញ់ការងារ ។ វាឆ្លាតនិយាយត្រូវតាមគំនិតអញ ។ ម៉ែវាចាំទេ កាលថ្ងៃសីលមួយយើងមកពីវត្តវិញអាចារ្យឆេងបានមកជំហារអួតពន្យល់យើងថា យើងរាស្ត្រត្រូវទទួលធ្វើការ ចិញ្ចឹមអ្នករាជការ ស្ដេចមន្ត្រី ដូចដៃជើងនៀយហាត់សំរាប់ក្រពះ ... ហើយយើងនៀយហាត់វេទនា ព្រោះយើងមិនបានកសាងពីជាតិមុនអោយបានក្រាស់ក្រៃល ។

ចំពោះរឿងនេះ អន្ទិតលឹមមានយោបល់ផ្ទុយ ។ បានឆ្លើយថា ៖ " យើងមិនត្រូវអណ្ដែតអណ្ដូងលើរឿងដែលយើងមិនដឹងពិតនោះទេ ។ យើងមិនអាចជដែកឃើញជាក់ស្ដែងថាជាតិមុន

យើងកើតជាអ្វី ហើយជាតិក្រោយក៏មិនដឹងទៅជាអ្វីដែរ ។ យើងត្រូវពិនិត្យមើលប្រវត្តិមនុស្សនៅលើដីនេះដែលមានហេតុភេទជាក់ស្តែង ។ យើងឃើញហើយថារាស្ត្រ ក្រីក្រសព្វថ្ងៃ គឺត្រូវពួកបារាំងជប៉ុនជិះជាន់ ។ ក្តីសុខ ក្តីសម្បូណ៌បានពិតប្រាកដដល់មនុស្ស បើកាលណាមនុស្សខំធ្វើការទាំងអស់គ្នាពិត ៗ ហើយគ្មានអ្នកមានអ្នកក្រ " ។ សំដីវានេះចំជាត្រូវ ។ អញដេកគិតទៅរឹតឃើញកាន់តែត្រូវកាន់តែពិត ។ នៅស្រុកយើងនេះ អុងប៉ាងថាវត្រូវជើងបារាំងសែស បានយកប្រាក់មកបុល ចងការហើយរាល់ឆ្នាំ អ្នកភូមិយើងបានលក់ស្រែអោយគាត់ធ្លាក់ទៅជាខ្ញុំគាត់ ។ នៅពេលយើងសព្វថ្ងៃពួកអុងប៉ាងថាវ បានត្រូវកងទ័ពជប៉ុនទិញឈើចំនេញរាប់លានរៀល ឯចំនែកយើងជារាស្ត្របានត្រូវពួកវាចាប់កេណ្ឌគូលី ។

ក្រៅពីចំនេះនិយាយត្រូវ អន្ទិតលឹមមានរូបឆោមមិនអន់ជាងកំលោះស្របាល ៗ វាទេនៅភូមិយើង ។ មើល៍ម៉ែវាយល់ឃើញយ៉ាងដូចម្តេច ?

អញយល់ដូចឪវាដែរ

អញស្មានថាឯងត្រូវយាយចាន់ភូមិត្បូងទាក់បានហើយ ឯងដឹងទេយាយចាន់នេះជាអ្នកដឹកញីប្រសុីឈ្មោល កុំទៅជឿគាត់ផ្តេសផ្តាស ។ មីខ្វែនភូមិដើមក្រសាំងធ្លាក់ខ្លួនអាវាសែសព្វថ្ងៃដោយកញ្ចាស់ចាន់មកបោកយកទៅអោចឺ ផែនទីដំបូង ។ តើឥលូវយើងស្របគ្នាស្រលាញ់លឹមហើយដូចនេះយើងត្រូវអោយក្រហេងគេចពីក្រញាំមេឃុំផាន់ ។ តាមអញ អញបានស្នើរជន្លងយើងរួចហើយ ថាអោយក្រហេងទៅនៅសំងំលាក់ខ្លួនឯផ្ទះគាត់ទំរាំដ់ថ្ងៃការ ។ តើឯងយល់ដូចម្តេច ?

ខ្ញុំយល់ស្រពេញទីតាមឪ ។ ខ្ញុំអាចជួយថែទាំងគាត់ផង ។

បើដូចនោះ ស្អែកទៅនៅជាមួយចុះ ។

....................................

# ៥ សង្គ្រាមចក្រពត្តិ

ក្រោកពីលឹមចេញទៅធ្វើគូលីជប៉ុន តាង៉ែតចាប់នឿយឡើងវិញ ។ គាត់ឃ្វាលគោរែកទឹក ។ ល ។ ឯចំនែកយាយម៉ុកក៏ត្រូវធ្វើការសព្វសាររពើក្នុងផ្ទះ ។ ពូស្វាយបានមកលេងនឹងគាត់ជាញឹកញាប់និយាយពីរឿងនាងហេង នឹងរកមធ្យាបាយបង្វែងដាននាងហេងពីមេឃុំផាន់ ។

ដូចសេចក្ដីសំរេច គ្រួសារពូស្វាយ នាងហេងបានមកនៅជាមួយតា ង៉ែត យាយម៉ុក ។ ចាប់តាំងពីនាងហេងមក លាក់ខ្លួនពួននៅផ្ទះគាត់យាយ តា ចាស់ ៗ រីកមុខរីកមាត់ នាងហេងបានជំនួសជើងដៃយាយម៉ុកស្ទើរគ្រប់កិច្ចការក្នុងផ្ទះ...។ នាងបោសសំអាតផ្ទះសំបែងរៀបចំបាយទឹក ។ រាល់យប់នាងដងទឹកដាក់ផ្តិលទុកបៀតសសរទ្រូង ហើយរៀបហិបស្លាជិតដំនេកយាយតា ។ នាងបានឆ្លៀតចុះទៅដីពេលស្ងាត់ដាក់ចំបើងមើលភ្នក់ភ្លើងគោ ។ ក្រោយពីបោសសំអាតនិងថែឆ្នាំងអំបែង នាងហេងបានរវៃរវល់ ៗ ល្ងាចស្ទើរតែគ្មានឈប់ ។

យាយម៉ុកពេញចិត្តកូនប្រសារគាត់ពន់ពេក គាត់បានលាន់មាត់ខ្សឹបប្រាប់ប្ដីគាត់ថា ៖ ឪវាឃើញទេ នាងហេងឧស្សាហ៍ធ្វើការណាស់ ។ វាស្រលាញ់កូនយើងពិត ។ ម៉ែ ៗ វារាប់ថ្ងៃគិតពេលអន្ទិតលឹមត្រលប់មកវិញ ។ វាសួរដំនឹងលឹមញឹក...។

តែសេចក្ដីរីករាយយាយតា មិនបានយូរទេ ។ មួយអាទិត្យក្រោយនាងហេងមកលាក់ខ្លួនជាមួយ ពូស្វាយបានមកត្រហេបត្រហបទាំងថ្ងៃត្រង់ឡើងទៅហៅយាយតានិយាយប្រាប់ស្ទើរតែដាក់ក្ដិតដល់កន្ទេលមិនទាន់៖

អ្នកដន្លងដឹងទេ ។ ពីព្រឹកមិញនេះ មេឃុំផាន់បាននាំប៉ូលីសបីនាក់ ប្រដាប់សុទ្ធតែកាំភ្លើងមករកចាប់ក្រហេង ។ ឥលូវទៅវិញហើយ តែបានស្រែកប្រាប់អ្នកភូមិថា អោយជួយរកក្រហេងពួនផង ។ មេឃុំផាន់ថាម៉េចអញ្ជឹងហើយ ។ បើដូចនោះឃើញថា ក្រហេង នៅផងមិនបានទេ ត្រូវអោយវាគេចទៅនៅឆ្ងាយ ។

ដំណើងធ្វើអោយតាង៉ែត ខឹងញ័រច្រលោតស្ទុះក្រោកចូលទៅក្នុង រើសយកដាវមួយចេញមក ។ គាត់និយាយដោយក្រោដថា ៖ អាផាន់នៅឯណា ! គ្នាវាប៉ុន្មាននាក់ ។ វាចង់ល្បងចាស់រឺ ? គុណដំបង រឺ ល្បុក្កតោប្រាប់មក ។ អញអោយទាំងអាផាន់ ទាំងប៉ូលីស វាយវាអោយបែកអំពិល

អំពែក វាចង់ស្លាប់រឺ ? ដាវនេះគឺកេរខ្មោចឪ ដែលបានកាន់យកទៅនៅទ័ពអាចារ្យស្វាវាបារាំង...។ មកនាងហេងកូនស្រីឪ ទៅជាមួយឪអោយអាផាន់ចាប់ល្បងមើល ។

ថាដល់ឃ្លានេះ គាត់ស្ទុះចុះទៅដី ។ យាយម៉ុកបានឃាត់ថា " ឪវាអើយ ! កុំខ្លាំងពេកឈប់ទៅ មេឃុំផាន់ទៅបាត់តែហើយ ។ ស្តាប់ដន្លងយើងនិយាយវិញ..." ។

លុះដល់តាង៉ែតរំសាយខឹង ពូស្វាយបានចាប់និយាយ " តាមខ្ញុំធ្លាប់ស្គាល់ផាន់មិនទុកអោយយើងសុខទេ ។ យើងទទឹងមុខគាត់មិនបានទេ ។ គាត់បានចាប់ពង្រាត់កូនគេបួនដងហើយ ។ កញ្ចាស់ចាន់ទៀតក៏ឆ្មើមណាស់ដែរ ដើរតែបោកលួងលោមដឹកញីប្រុសុីឈ្មោលយើងត្រូវរកវិធីអោយក្រហេងចេញពីភូមិ ។ នៅនេះទៀតមិនបានទេ។ តាមយោបល់ខ្ញុំ ។ ស្នើអោយដន្លងទៅលក់អង្ករឯភ្នំពេញ នាំក្រហេងទៅជាមួយផង ដល់ត្រលប់មកវិញ ត្រូវនៅសំរាកតាមស្រុកចំការទិញបន្លែត្រលាច ល្ពៅ ឃ្លោក សំរាប់ការកូនយើង ។ ត្រូវសំរាកនៅចំការយូរបន្តិច បង្អង់ជិតថ្ងៃការចាំមកហើយពេលនោះអន្ទិត លឹម ត្រលប់ពីពោធិចិនតង់វិញ ។

សេចក្តីស្នើរពូស្វាយបានទទូលយល់ព្រមគ្រប់គ្នា ។ តា ង៉ែត យាយ ម៉ុក នាងហេងបានទទូលរួមគ្នាខំធ្វើអង្ករ ។ តែពីរយប់គាត់ផាន់បាន ៥ ហាប ផ្ទុកដាក់រទេះរួចស្រេចគាត់ក៏បបូលគ្នាទាំងបីនាក់បររទេះគោមកឡើងថ្នល់ខាងលិចភូមិ ហើយបរមកជើងសំដៅទៅភ្នំពេញ ។ នៅលើថ្នល់រទេះឡានឈ្នួល រទេះឡានសឹកជប៉ុន រទេះឡានតូចរបស់លោកបារាំងខ្មែរ បានបើកវឹចុះវឹឡើងឆាបបង្ហើលរទេះគោអោយធ្លាក់ថ្នល់ ។ នាងហេង និង យាយម៉ុកជិះរទេះ ។ នាងហេងបរ តាង៉ែតដើរមុខរទេះចាំចាប់រទេះគោវេលាដែលមានរទេះឡានដែង រឺ ចៀសរទេះគាត់ បរបានមកដល់ចាក់អង្រែក្រោមតា ង៉ែត បញ្ឈប់រទេះគាត់អោយគោសុីស្មៅ ហើយបបូលកូនប្រពន្ធបាយថ្ងៃនៅលើសាលាឆទានមួយគ្មានជញ្ជាំង ។

ថ្ងៃរសៀលតាង៉ែតចាប់គោទឹមឡើងបរទៅទៀត ។ គាត់បរបណ្តើរគាត់ខឹងរោលរាលបណ្តើរ ។ គាត់ប្រាប់ប្រពន្ធកូនថា ៖

ថ្នល់អស់នេះសុទ្ធតែអញឆ្កា អញកាប់ អញលើក អញរែកដីចាក់ទាំងអស់ ។ គ្មាននរណាធ្វើក្រៅពីរាស្ត្រទេ ។ ដល់ឥលូវបានចាក់ជ័រស្អាត គេបែរជាឃាត់ទាំងមិនអោយអ្នកស្រែបររទេះគោផងដោយគេថាដែកកង់ជីកខូងដីអោយឆាប់ខូចថ្នល់ ។ ធម្មតារាស្ត្រមិនដែលបានបេះផ្លែផ្កាពីញើស

ឈាមរបស់ខ្លួនទេ...។

តាង៉ែតនិយាយត្រង់នេះបន្តិចត្រង់នោះបន្តិចអោយចប់តាមផ្លូវ ។ មកដល់ក្បាលស្ពាន ជ្រោយតាអោកចូលទីក្រុង តាង៉ែតហុចខ្សែគោទៅអោយនាងហេងបរវិញ ហើយរអ៊ូប្រាប់ប្រពន្ធកូន ថា ៖

អាផាន់ហ៊ានប្រមាថមើលងាយអញមែន ។ វាប្រើអំនាចមកចាប់កូនប្រសារយើងនាំអោយ យើងអំពល់មកលក់អង្ករភ្នំពេញ ក្នុងស្រុកគេមានសង្គ្រាម ។

ពេលនេះភ្នំពេញស្ងាត់មានមនុស្សដើរមួយ ៗ រទេះឡានសឹកជប៉ុន បានធ្វើជាម្ចាស់ក្រុង ភ្នំពេញបើកលឿនច្រវាត់មើលតែហោះរូចុះរូឡើង ចេញពីបន្ទាយមួយទៅបន្ទាយមួយដែលបោះនៅ គ្រប់សាលារៀនក្រុងភ្នំពេញ ។ អ្នកក្រុងមានធនធានបានបណ្តោះប្រពន្ធកូនទ្រព្យសម្បត្តិ អោយ ជូលផ្ទះនៅស្រែចំការគេចគ្រាប់បែក ។ ឯចំនែកអ្នកក្រុងទាល់ក្រវិញមិន ដឹងរត់ទៅពួននៅកន្លែង ណា ក៏នៅរកស៊ីធ្វើគូលីរងគ្រាប់បែកចាំតែស្លាប់នៅភ្នំពេញ ។ ខ្លះស៊ីឈ្នួលចាំយាមផ្ទះអោយគេ ។ អ្នកចំការភាគច្រើនឈប់យកបន្លែមកលក់ផ្សារភ្នំពេញ ហើយអ្នកស្រែក៏មិនសូវដឹកអង្ករ ស្លឹក អុស មកលក់ដែរ ។

ហេតុនេះវេលាឃើញរទេះអង្ករតាង៉ែត ចិន វៀតណាម ខ្មែរ ត្រេកអររត់ចេញពីផ្ទះមក ដណ្តើមគ្នាទិញ ។ ខ្លះទិញមួយចុង ខ្លះទិញបីតៅ ខ្លះទិញដល់ហាប ។ តែមួយផ្លូវពីវត្តតាកែវមក ស្ពានកូនកាត់ តាង៉ែតលក់អង្ករដាច់អស់ ។ គាត់ត្រេកអរលាន់មាត់ប្រាប់ប្រពន្ធកូនថា ៖ ចំណែក ណាស់លើកនេះ លក់ឆាប់ដាច់ ហើយមិនឡើយពញាយនាយមួយម៉ាត់ផង ។

គាត់បរសំដៅទៅផ្សារស៊ីលិបសំរាកឈប់យប់នៅកន្លែងខាងត្បូងផ្សារ ។

ពេលយប់ភ្នំពេញស្ងាត់ជាងពេលថ្ងៃទៅទៀត ។ រាជការបានគ្របចង្កៀង តាមផ្លូវកុំអោយ មានពន្លឺចាំងឆ្ងាយការពារកុំអោយយន្តហោះមើលដឹងជាទីក្រុង ។ តាង៉ែតគ្មានហ៊ានទៅឆ្ងាយពីរទេះ គាត់ទេ ។ គាត់បបួលកូនប្រពន្ធគាត់សំរាក ដើម្បីនឹងយកកំលាំងបររទេះព្រឹកត្រលប់ទៅចំការវិញ ។

លុះព្រឹកឡើងតាង៉ែតបានដាស់ប្រពន្ធគាត់អោយដាំបាយ រៀបចំប្រដាប់ប្រដាដាក់រទេះ ហើយគាត់ក៏បររទេះយកអង្ករមួយតៅប្រគេនលោកក្មួយគាត់ដែលគង់នៅវត្តប្រលោម ។

ភ្នំពេញមិនបានសុខសប្បាយជាទេ លោះថ្ងៃតិចណាស់អ្នកក្រុងមិនរត់ចូលរូងត្រង់សេ ។ ស្ទើររាល់ព្រឹកល្ងាច យប់កញ្ជៃ លឺ ដូចផ្គេលូបញ្ចេញសូរសព្ទប្រាប់អ្នកក្រុង អោយរត់ពួនលាក់ខ្លួច គេចគ្រាប់បែកថាមានយន្តហោះ អាមេរិចកាំងមកទំលាក់គ្រាប់បែកសំលាប់ ។ នៅលើចញ្ចើមថ្នល់មានជីករូងត្រង់សេក្រងិចក្រងក់ទុកសំរាប់អោយអ្នកដំនើររត់ចូលពួន នៅពេលយន្តហោះខ្មាំងមកដល់ ។ តាង៉ែតឃើញស្ថានការណ៍ដូចនេះបារម្ភជាខ្លាំងក្នុងចិត្ត ។ គាត់មិនធ្លាប់រត់គ្រាប់បែក ។ បើកញ្ជៃស្រែក គាត់មិនដឹងជារត់ចោលរទេះគោយ៉ាងណាហើយមិនដឹងជានាំប្រពន្ធកូនរត់ទៅខាងណា ។ គាត់បររទេះបណ្ដើរ គាត់គិតបណ្ដើរ ។ គាត់ខំដេញគោអោយដើរលឿនលើផ្លូវក្រោយវត្តបូទុម រួចបត់តាមផ្លូវវាលមេរុខាងជើងវាំង ។ ដល់ជ្រុងខាងត្បូងវាលមេរុផ្លូវផ្សារស៊ីញ្ញែក គាត់កាច់រទេះគាត់តំរង់ទៅជើងចំមុខវត្តប្រលោម ។ មកដល់មុខវត្តប្រលោមបៀតរូបស្តេចគំលង់ តាង៉ែតបញ្ឈប់រទេះ ។ កំពុងយកអង្ករមួយល្អីពីរទេះ ស្រាប់តែលឺសំលេងផ្គេលូ មុនដំបូងល្ហើយ បន្តិចទៅខ្លាំងឡើង ៗ ប្រាប់ថាមានយន្តហោះអាមេរិចកាំងមកទំលាក់គ្រាប់បែក ។ យាយម៉ុកភ័យឆោឡោស្រែកឪវាយើងទៅខាងណា ។

តាង៉ែតទំលាក់អង្ករចោលនាំប្រពន្ធកូនគាត់ចូលទៅវត្តចោលរទេះចោលគោ ។ កញ្ជៃឈប់ស្រែក សូរស័ព្ទសន្លឹកយន្តហោះបានបញ្ចេញលឺសូរក្អុលធ្ងន់ ហើយមួយស្របក់ក្រោយគេលឺមាត់មនុស្សច្របូកច្របល់គ្នា ៖

លើកនេះមកមែនទែនហើយ ។ សូរនេះមិនមែនយន្តហោះជប៉ុន ។ បបួលគ្នាក្រាបប្រយ័ត្ន...។

មើលគ្រោះថ្នាក់មិនឃើញទេ ញាតិញោមអើយខំភាវនាធម៌ទៅ !

យាយម៉ុកភ័យស្លាំងបានទន្ទេញញាប់មាត់ថា ៖ " ព្រះពុទ្ធ ! ព្រះធម៌ ! ព្រះសង្ឃ ! "

នាងហេងភ័យញ័រមាត់ បានខ្សឹបសួរតាង៉ែតថា ៖ បើយើងមានគ្រោះថ្នាក់តើបងលឹមទុក្ខសោកយ៉ាងណាទៅ ? តើម៉ែឪខ្ញុំព្រួយដូចម្ដេចទៅ ?

តាង៉ែតបានកំលាលើកទឹកចិត្តប្រពន្ធគាត់ថា ៖ " កុំភ័យព្រួយហួសពេក វាគ្មានអ្វីទេ ។ ខំនឹកគុណរតនត្រ័យ... ។ ស្រេចលើព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ។

យន្តហោះកាន់តែមកជិត សូរញ័រកក្រើកដី ។ សំលេងខ្សឹបខ្សាវច្របូកច្របល់ក៏ផុសចេញ

ឡើងពីត្រង់សេ ៖

មកមែនហើយ ខំក្រាបអោយស្រួល ប្រយ័ត្នកុំយកដើមទ្រូងដាក់ផ្ទាល់លើដី ។

មកដល់ដប់ ។

ហេតុអ្វីក៏ជប៉ុនមិនឡើងទៅដេញបាញ់ ?

កុំព្រួយអ្វី គេមិនទំលាក់លើវត្តទេ ។ គេទំលាក់តែលើ ឃ្លាំងកាំភ្លើង រំសេវ តែលើបន្ទាយទាហាន....។

គ្រាប់បែកគ្មានស្គាល់វត្តអារាម គ្មានស្គាល់សង្ឃ គ្មានស្គាល់គ្រហស្ថ គ្មានស្គាល់ផ្សារ គ្មានស្គាល់បន្ទាយឡើយ ។ សង្គ្រាមបង្ខិនបង្ខោចគ្រប់គ្នា ។ ក្នុងពេលច្របូកច្របល់ខ្លះយំខ្លះបន់ទេព្តាបន់ព្រះ ខ្លះស្រែករកម៉ែឪជូនតា យន្តហោះបោះពួយ ចុះលឿនរ៉ ហើយត្រលប់ឡើងទៅវិញ ជំរុះគ្រាប់បែកធ្លាក់ចំចេតិយធំមុខស្តេចគំលង់ ។ ដីថ្មល់ស្មើរាបក៏បានប្រែទៅជាស្នាមភ្លោះជ្រៅ ចេតិយក៏បានរលាយបាក់បែក ខ្ទេចខ្ទី ។ អ្នកនៅជ្រកកោនពួនពឹងផ្ញើជីវិតនឹងចេតិយ បានខ្លះខ្ទាតដាច់ពីគ្នាហើយខ្លះត្រូវដុំថ្មសង្កត់លើ ។ តាង៉ែត យាយម៉ុកនាងហេង បានខ្ទាតចេញពីគ្នាមិនដឹងខ្លួន ។ គ្រាប់បែកបានលើកនាងហេងក្រវែងចោលទៅឆ្ងាយ ហើយបានទាំងនាំដុំថ្មមួយយកទៅសង្កត់ដើមទ្រូងនាងទៀត ។ នាងមានឈាមចេញពីមាត់ ។ នាងនិយាយមិនចេញ ហើយបែបចង់ហាមាត់ស្រែកហៅគេឯង រឺនឹកដល់គួរសំលាញ់ រឺដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ការបន់ស្រន់ទាំងប៉ុន្មានជួយនាងមិនបាន ។ នាងក៏ចាកឋានទៅជាមួយម៉ែឪក្មេកនាងព្រមនឹងប្រជាជនចិន វៀតណាម ខ្មែរ ច្រើនរូបទៀត ។

សង្គ្រាមចក្រពត្តិបានកំទេចផ្ទះច្រើនខ្នងនៅក្រុងភ្នំពេញ បានធ្វើកូនកំព្រាឪពុកម្តាយ បានធ្វើអោយម្តាយព្រាត់កូន បានធ្វើអោយអ្នកមានផ្ទះរកផ្ទះជ្រកគ្មាន...។

.....................................

# ៦ កំនែននៅពោធិចិនតុង

... រាល់ព្រឹកម៉ោង ៦ ជប៉ុនបានប្រមូលគូលី ហៅឈ្មោះរួចចាត់អោយទៅធ្វើការរៀងខ្លួន ។

អ្នកកំនែនរទេះ ត្រូវជប៉ុនចាត់អោយទៅដឹកថ្ម ។ អ្នកមានតែសំបកខ្លួនត្រូវវាចាត់ទៅធ្វើការផ្សេងទៀត ។ ខ្លះត្រូវចាត់ទៅកាប់កូនឈើ ។ ខ្លះត្រូវបង្ខំអោយជីករូងត្រង់សេ...។

ឯចំនែកលឹម និង តាមុយត្រូវជប៉ុន ចាត់អោយជញ្ជូនដុំថ្មក្រាលវិសផ្លូវយន្តហោះ ។

ពោធិចិនតុងពេលនេះ ជាកន្លែងប្រមូលផ្តុំអ្នកស្រែចំការពីគ្រប់ខេត្ត ។

នាយអ៊ួចនៅស្រុកកណ្តាលស្ទឹងមិនទាប់កាន់កាតលេសេផងក៏ត្រូវជាប់កំនែនជប៉ុនដែរ ។ វាមកជួសឪវាដែលរវល់ចាំពោះម៉ែវា ។ តាស៊ឹមអាយុ ៦០ ឆ្នាំ នៅខេត្តកំពង់ស្ពឺក៏ត្រូវវាជការកេណ្ឌយកមកដែរ ។ ពូប៉ូញាចំនាស់ពាក់កណ្តាលមនុស្សមកពីខេត្តតាកែវ ។ ពូធុច និង គ្នាគាត់ច្រើនទៀតដែលបានគេចកំនែន ឧត្តុង្គ មករកស៊ីក្រុងភ្នំពេញ ក៏ត្រូវគេចាប់គៀរយកមកដែរ ។ ស្រីខ្មែរវៀតណាម ចាស់ក្មេង ក៏បានមកជាប់គូលីតាមឡានជប៉ុនដែរ ។ ល ។

ធ្វើការយូរថ្ងៃទៅ កំនែនដែលនៅក្នុងក្រោលរបងលួសបន្លាព័ទ្ធជុំវិញ បានស្គាល់រាប់អានគ្នាទៅវិញទៅមក ។ កំនែនដែលមានឋានៈដូចគ្នា ទទួលការជិះជាន់ដូចគ្នា បានចេះរំលែកចែកទុក្ខលសោកគ្នា ។ កំនែនឧស្សាហ៍ប្រជុំជជែកគ្នាលេងជាក្រុមៗ សួររកហេតុភេទដែលបណ្តាលអោយខ្លួនវេទនាអោយជប៉ុនចូលស្រុក អោយបារាំងជិះជាន់ ធ្វើបាបប្រជារាស្ត្រ ។

ការប្រជុំជជែកគ្នាពេលល្ងាចរួចបាយ ជាទំលាប់មួយនៃពួកកំនែន ។ គេជជែកគ្នាតែសព្វតែគ្រប់ ។ ខ្លះត្អូញប្រាប់គ្នាពីការប៉ូវាលគំហកកំហែងពីថ្ងៃ ។ ខ្លះខឹងនឹងជប៉ុនវាយក្បាល ។ ខ្លះនិយាយរឿងសាស្ត្រល្បែងជិនវង្ស សង្ខសិល្បជ័យ ។ ខ្លះនិយាយរឿងធ្មេញជ័យ ។ ខ្លះច្រៀងរឿង អាឡេវខ្លះទៀតនិយាយរឿងគ្រួសារ ដែលខ្លួនត្រូវបង្ខំចេញចោលមក ។ នៅយប់មួយជាយប់ខែភ្លឺព្រះចន្ទពេញវង់ កំនែនបានប្រជុំគ្នាជាច្រើនវង់ ។ មួយវង់ ៗ មានគ្នាជាប់ម្ភៃនាក់បាននិយាយពីនេះពីនោះ ។

ក្នុងវង់ដែលលឹមនៅជាមួយតាមុយចាស់ជាងគេ បានចាំរឿងបារាំងធ្វើបាបច្រើនបានផ្តើមសួរ ៖

ដល់ថ្ងៃណាបានយើងឈប់ជាប់កំនែន ។ ខ្ញុំតាំងពីកើតមកជាប់កំនែនរាល់ឆ្នាំ ។ បន្តិចត្រូវគេកេណ្ឌធ្វើថ្នល់ បន្តិចត្រូវគេកេណ្ឌធ្វើផ្សារ...។ ឆ្នាំនេះជាប់កំនែនជប៉ុនពីរលើកហើយ ។

សំលេងមួយបានឆ្លើយកាត់ ៖

បើចង់រួចកំនែនមានតែកុំធ្វើរាស្ត្រ ព្រោះរាស្ត្រត្រូវធ្វើខ្ញុំគេ ត្រូវធ្វើកំនែន ។ បើចង់កុំអោយជាប់កំនែនត្រូវធ្វើនាម៉ឺន ត្រូវទៅបំរើព្រះអង្គម្ចាស់ណាមួយនៅភ្នំពេញ...។

ធ្វើនាម៉ឺនទាំងអស់គ្នាដូចម្តេចបាន ។ ហើយបើធ្វើអស់ទៅបាននរណាធ្វើស្រែ ។ តំនែងនាម៉ឺនមានតិចណាស់មិនគ្រប់គ្នាឡើយ...។ (តាមុយបានឆ្លើយ ) ។

តាឡេនមាឌតូច ទាបបានអោយយោបល់ថា ៖

ដល់ជប៉ុនឈប់ច្បាំងកាលណា យើងលែងជាប់កំនែនទៀតហើយ...។

តាច្រលំហើយ ! ( សំលេងច្រើនស្រែក ) ។ កំនែនមានតាំងពីមុនជប៉ុនម្ល៉េះ ។ សង្គ្រាមឈប់យើងក៏នៅតែធ្វើកំនែនដដែល ។

ចុះគិតដូចម្តេចទៅ អោយរួចពីកំនែន ។ ខ្ញុំទាល់ហើយ មួយជីវិតនេះស្គាល់តែគេកេណ្ឌ ហើយស្គាល់តែគេកំហែង ត ៗ គ្នាមកថា ៖ ប្រយ័ត្នបារាំងចាប់ បារាំងបាញ់ បារាំងពោល បារាំងដោតបារាំងកាត់ក... បើមិនបង់ពន្ធអោយឆាប់ បើរឹងរូសមិនធ្វើកំនែន...។

នៅមុខពាក្យសួរតាឡេង កំនែនគ្រប់គ្នាដែលបានស្តាប់នៅស្ងៀមទ្រឹង ។ តែមួយស្របក់ក្រោយ សំលេងច្រើនបានបញ្ចេញយោបល់ប្លែក ៗ គ្នា ។ អ្នកដែលបានសំងំខ្លះ ក៏ជួយអោយយោបល់ដែរ ។ គេលឺសំលេងឆ្លើយឆ្លង ៖

មានតែហ្លួង តែកុងសីទេ ដែលអាចដោះពាក្យសួរតាឡេង !

យើងរាស្ត្រគិតអ្វី ! កុំខ្វល់រឿងស្រុកទេសនោះ នៅមុខយោបល់ខ្វែងគ្នាដូចនេះលឹមបានមួយ ៗ ហុចយោបល់ថា ៖

នៅក្នុងសង្គមខ្មែរយើងមានក្រុមពីរ ក្រុមបារាំង ជប៉ុននិងដៃជើងរបស់វា ជាមេប្លន់ជិះជាន់សង្កត់សង្កិនយើងគ្រប់គ្នា ដើម្បីគេនៅដេកស៊ីស្រួល និងក្រុមប្រជារាស្ត្រដែលមានយើងទាំងអស់គ្នា

ជាអ្នកបង្កើនផល ។ ពួកបារាំង ជប៉ុន ជាអ្នកជិះជាន់យើង ហេតុនេះបើចង់ចេញផុតពីកំនែនពីការតោកយ៉ាកដូចសព្វថ្ងៃ ទាល់តែយើងចេះរួបរួមគ្នាទាមទារសេរីភាព សិទ្ធិអោយដូចស្រុកប្រជាធិបតេយ្យ ...។ យោបល់លឺមមិនបានបំបាក់ការខ្វែងគ្នាទេ ។ សំលេងត្អូះតិះដៀលនិងសាទរបានលេចឡើង ៖

កុំមកភេ ! មិនជឿរទេ

ពិតជាត្រូវហើយ តែធ្វើមិនកើតទេ !

ដេកទៅ កុំធ្វើអ្នកប្រាជ្ញអី ! ស្អែកចាំជដែកទៀត.....

កំនែនតំលើងសរសៃកស្រែកដាក់គ្នា លាន់ខ្លាំងខុសធម្មតា ។ ជប៉ុនបានលឺស្នូរតែគូលីរត់បានបាញ់កាំភ្លើងទៅលើប្រាប់ពួកវាអោយប្រុង ។ គូលីលឺស្នូរកាំភ្លើងឈប់ជជែកហើយភ្លាមៗ បានលូនវារត់ទៅកន្លែងដេក សំងំស្ងាត់ស្ងៀមស្ងួនឡឈឹង...។ ទាហានជប៉ុនបានរត់ស្រ៊ុសៗ សំដៅមកឈ្លោកមើលរបងលួសបន្លា មើលជុំវិញគ្មានឃើញអ្វីក៏ត្រលប់ទៅយាមវិញ...។

.....................................

# ៧ ថ្ងៃបង្ហើយ

ខ្មែតផុត រនោចចូល ។ លោកចេះតែដើរប្រែជានិច្ច ។ កងទ័ពផាស៊ីសហ៊ីត្លែរបានត្រូវចាញ់ដៃនៅស្តាលីនក្រាត ។ កងទ័ពក្រហមសហភាពសូវៀតបានរំដោះមួយម្តង ៗ ទីក្រុងនិងប្រទេសអឺរ៉ុបខាងកើតពីក្រញាំងដៃហ៊ីត្លែរ ។ វ៉ាសូវីបានរំដោះ ។ ភ្នំពេញបានត្រូវគ្រាប់បែកអាមេរិចកាំងកំទេចអស់ផ្សារកណ្តាល អស់ផៃ អស់ចេតិយវត្តប្រលោម កូនព្រាត់ម៉ែ ឪ ប្តីព្រាត់ប្រពន្ធ ។ ផាស៊ីសជប៉ុនចេះតែខំទាត់អាណានិគមនិយមបារាំងចេញបន្តិចម្តងៗ យកអំនាចកាន់ផ្ទាល់ហើយបោកកុហកឃោសនាអូសខ្មែរអោយចូលទៅក្នុង " ក្រុមផ្កាយខ្មៅ " ធ្វើសង្គ្រាមមហាអាស៊ី ។ គូលីកំនៃនពោធិចិនតុងក៏បានផ្លាស់ប្តូរដែរ ។ គូលីថ្មីចូល គូលីចាស់ចេញ ។ លឹមក៏បានដល់ថ្ងៃរួចកំនៃន ។

នៅថ្ងៃបង្ហើយ កន្លែងធ្វើការក្រោលវិសផ្លូវយន្តហោះមានសកម្មភាពខុសធម្មតា ។ កាប៉ូរ៉ាល និង ជប៉ុនបានធ្វើបញ្ជីបុងបញ្ជីលុយ ។ សំដីជូរចត់ គំហកកំហែង ត្អូញត្អែររីករាយបានលាន់លឺចំរុះគ្នា ។

រួចខ្លួនហើយល្ងាចនេះ ! ទៅផ្ទះទាំងយប់ហើយ មិនទ្រាំនៅទៀតទេ !

តាឯងទៅព្រឹក រឺ ល្ងាច ?

កុំគិតតែជជែកគ្នា ខំធ្វើការអោយឆាប់ទៅ ប្រយ័ត្នមិនអោយសំបុត្របញ្ជាក់ ។

លឺកាប៉ូរ៉ាលស្តីដូចនេះ តាមុយខ្សឹបប្រាប់លឹមថា ៖ មិនមែនតែកន្លែងនេះទេ ។ នៅគ្រប់កន្លែងធ្វើការតែដល់ថ្ងៃបើកលុយ កាប៉ូរ៉ាលរករឿងសំបើមណាស់ ។ គេតែងរករឿងបន្ទោសថាគូលីខ្ជិលហើយគេត្រូវតែកាត់ប៉ុននេះប៉ុននោះថ្ងៃ បើពុំនោះគេថាលុយគ្មាន បើកមិនទាន់បានចាំថ្ងៃក្រោយ ។ ចឺនេះក៏ណាស់ដែរ ។ គាត់ត្រូវផ្លុងមួយនឹងជប៉ុន ។ គាត់ថាបើកអោយយើងតែម្តៃថ្ងៃ ហើយដប់ថ្ងៃគាត់អោយបុងជំនួស...។

ចឺកាប៉ូរ៉ាលគាត់បាននិយាយស្តីទិញបុងដប់ថ្ងៃរបស់ខ្ញុំ អោយតែថ្លៃតែប្រាំថ្ងៃ ។ គាត់អោយលុយយើងដល់ដៃ ។ តើតាគិតដូចម្តេច ? លក់ រឺ ទុកបុងបើកថ្ងៃក្រោយ...។

យើងលក់យកលុយភ្លាមទៅល្អជាង ។ ចាំថ្ងៃក្រោយខាតទាំងអស់ កុំថា ៥ ថ្ងៃ ។ មួយថ្ងៃក៏

មិនបានដែរ ។ កាលពីឆ្នាំទៅ តាបានធ្វើគូលីកំនែននៅក្បាលថ្នល់ ។ តានៅសល់បុងមួយសព្វថ្ងៃ បើកមិនបានទាល់តែសោះ មិនដឹងបើងណា សួរត្រាវ៉ូថាផ្ញើមកសាលាស្រុក សួរសាលាស្រុកថានៅសាលាឃុំ ។ ប្ដឹងដល់សាលាខេត្តបាត់ឈឹង លែងលឺដំនឹងរហូតមកដល់សព្វថ្ងៃនេះ...។

នេះបានចំជាជិះជាន់យើងមែន ។ ( លឹមបានលាន់មាត់ ) គេគិតតែចំនេញតែហោប៉ៅតែគ្រួសារគេ យើងងាប់ ក៏ងាប់ចុះ...។

កុំនិយាយខ្លាំងពេកតិចលឺដល់ជប៉ុន ។ ទ្រាំទៅនៅប៉ុន្មានម៉ោងទៀតទេ យើងបានបើកលុយ បានសំបុត្ររួចខ្លួនហើយ...។

ផុតម៉ោងធ្វើការគ្រប់កំនែនដែលត្រូវរួចខ្លួន បានបើកលុយលក់បុងអោយកាប៉ូរាលខាតពាក់កណ្ដាល ហើយបានសំបុត្របញ្ជាក់មួយពីជប៉ុន គូលីមានផ្ទះជិតបានទៅទាំងយប់ ។ ឯគូលីណានៅផ្ទះឆ្ងាយនៅសំនាក់មួយយប់ ទៀតក្នុងក្រោលជំរុំរបងបន្លា ។

លឹមមិនបានត្រលប់ទៅស្រុកទាំងយប់វិញទេ ។ គាត់បានអោយអំបិល ប្រហុកអង្ករនៅសល់ទៅនាយអ៊្វិចដែលនៅជាប់កំនែន ៥ ថ្ងៃទៀតបានរួច ។ នៅយប់នេះកំនែនខ្លះដែលបានជជែកក្នុងវង់លឹមពីថ្ងៃមុនបានមកប្រជុំគ្នាទៀត លឹមបាននិយាយពីរឿងវិវឌ្ឍន៍សង្គម តាំងពីមានមនុស្សលើដីមកការបដិវត្ត នៅប្រទេសបារាំង ពីការបដិវត្ត នៅរុស្ស៊ី ពីលទ្ធិប្រជាធិបតេយ្យ ពីសេរីភាព ពីសិទ្ធពីកំនើតទុក្ខវេទនានៃប្រជាជនខ្មែរ ។ តាស៊ឹមនាយអ៊្វិច តាឡេងបានស្ដាប់ជក់ស្លុង ។ តាមុយបានបន្ទុចបង្អាក់ជាញឹក ៖

ឯងនិយាយមិនសមទេ ! អញមិនជឿឡើយ !

នាយអ៊្វិចបានកាន់ជើងលឹម ៖

តាកុំអាលមាត់ទុកអោយបងលឹមនិយាយចប់សិន !

តាមុយមិនបានស្ដាប់ទេ គាត់មានៈបញ្ឈប់លឹម ហើយគាត់បន្ទោសថា ៖

ឯងនិយាយពិតមែនរឺ ? កុំឃើញតែគេលូង់ចេះតែភរទៅ ! វាមិនដែលស្រុកមានរាស្ត្រសំបូរសប្បាយនោះ ។

អញកើតជាប់ ៦០ ឆ្នាំ មិនដែលនរណានិយាយផ្ដាស់ដូចឯង ! អញឃើញតែរាស្ត្រវេទនា

តែរាស្ត្រខ្វះស៊ីបំរើគេ ។ សាស្ត្រទេស សាស្ត្រល្បែងទៀត ដែលអញបាន់មើលទាំងគម្ពីរ ៗ ក៏មិនឃើញរាស្ត្រស្រុកណាសប្បាយឡើយ ។ ទោះនៅស្រុកជិនវង្ស នៅស្រុកទសកណ្ឋ ឃើញតែគេកេណ្ឌរាស្ត្រទាំងសមុទ្រ ៗ អោយកាប់សំលាប់គ្នា ដណ្តើមស្រីប្ញទុមសុរិយា...។ នៅសម័យព្រះទៀតក៏ឃើញតែពូជសក្យះ ពួកព្រាហ្មណ៍ខំតំកើងពូជពង្សរបស់ខ្លួនទំលាក់ប្រជារាស្ត្រអោយលុតក្រាបបំរើខ្លួន ។ វាចំលែកណាស់ឯងនិយាយទាំងប៉ុន្មាននោះ ! មើលឯងដែលបានទៅឃើញស្រុកនោះរឺ ?

ស្រុកដែលខ្ញុំនិយាយនេះនៅលើដីពិត មិនមែននៅស្ថានទេវលោក ឋានលើឡើយ ។ តាមគ្រូខ្ញុំប្រាប់ខ្ញុំ គាត់ថាលទ្ធិប្រជាធិបតេយ្យពិតប្រាកដដែលបានមានកំនើតនៅឆ្នាំ ១៩១៧ ដោយកំលាំងប្រជាជន គូលី ជាង អ្នកស្រែដណ្តើមយកបាន មុខជារីកមុខជារាលដល់គ្រប់ស្រុក...។ គាត់ថាគង់តែភ្នំព្រះសុមេរុនោះ ក៏មិនអាចទប់ទល់កំលាំងប្រជាធិបតេយ្យនោះបានឡើយ...។

ស្អីលោកគ្រូម៉ក់សូត្រស្តាំវត្តត្បូងនោះ លោកគ្រូប្រាជ្ញហួស ហើយកុំតែ រហ័សវេះទៅស្រុកសៀមទាន់ កុំអីបានដៃបារាំងចាប់ទៅកោះត្រឡាចស្រេច ! អញមិនជឿទេ គ្រូម៉ក់នោះ...!

ប៉ូញបានកាត់

បើតាមិនស្តាប់ ទុកអោយយើងស្តាប់ ។ អន្ទិតលឹមនិយាយពន្យល់យើងពីទុក្ខវេទនារាស្ត្រនោះវាត្រូវហើយ ។ ធម្មតាបើយើងរាស្ត្រមិនប្រឹងគ្មាននរណាដោះទុក្ខអោយប្រជាជនយើងទេ ។

តាស៊ឹមបានបន្ថែម ៖

ប្រាកដជាមកមែន រឺ ប្រជាធិបតេយ្យនោះ ! តាចាស់ហើយ ! ក្មេងជាប់ក្រោយគេសប្បាយហើយ !

កុំជឿអន្ទិតលឹមវាភរ ! មកទៅដេក ! កុំនិយាយដល់ណាទៀត តិចជប៉ុនមកបាញ់ទៀត ។ ពាក់កណ្តាលអធ្រាត្រហើយ ។ ស្អែកយើងត្រូវដើរទៅភូមិ ។

ថាចប់តាមុយកេះតាស៊ឹមនិងប៉ូញទៅដេក ហើយវង់ប្រជុំក៏បានបែកគ្នា...។

………………………………….

# ៨ សល់តែសំបកខ្លួន

លុះព្រឹកស្រាង ៗ មុនពេលកំនៃនចេញទៅធ្វើការ លឹមបានលាគូកនគាត់ ដើរចេញពីពោធិចិនតុងជាមួយតាមុយ ។ ដល់កំពង់ទួល គាត់ទិញចេកមួយស្និត ផ្លែម្នាស់មួយ ផ្ញើជូនម៉ែ ឪគាត់ ។ នាក់ទាំងពីនាក់បានខំដើរយ៉ាងលឿនមកដល់ភូមិដើមអំពិលពេលលោកទ្រង់បាត្រ ។

នៅផ្ទះលឹមបង ៗ គាត់មកប្រជុំគ្នា ។ ស្រី ៗ កោសក់ ពូស្វាយមីងពក ក៏បានមកជុំនៅផ្ទះនោះដែរ ។ ពូស្វាយឃើញលឹមមកដល់បានចុះទៅនិយាយលួងលោមថា ៖

មិនមែនតែយើងទេព្រាត់ប្រាស់នោះ...។ ពុក និងបង ៗ ឯងគ្មានប្រហែសទេ ។ ក្រោយដែលបានដឹងថាជន្លងនិងក្រហេងស្លាប់នឹងគ្រាប់បែក យើងបបួលគ្នាទៅភ្នំពេញភ្លាម ។ យើងខំពិនិត្យមើលសពទាំងបីច្បាស់ក៏ហែយកមកបូជាទៅវត្តបូទុម ។ មានគ្រួសារច្រើនណាស់មិនទាន់រកខ្មោចឃើញ ។ ថ្ងៃនេះ យើងបានប្រជុំគ្នាធ្វើបុណ្យរំលឹកគាត់ម្តងទៀត...។

ដំនឹងនេះបានធ្វើអោយលឹមធ្លាក់ទឹកភ្នែកមុខក្រៀមភ្លាម ។ គាត់បានឡើងទៅលើផ្ទះគោរពវិញ្ញាណក្ខន្ធ នៃបុគ្គលទាំងបីដែលនៅសល់ជាធាតុបីកញ្ចប់ដំកល់លើជើងពាន...។

បីថ្ងៃក្រោយមកមន្តលោកឆាន់បុណ្យខ្មោច តាង៉ែត នាងហេង បងប្រុស ស្រីលឹម និង ភ្ញៀវជិតឆ្ងាយបានត្រលប់ទៅផ្ទះរៀងខ្លួន ។ លឹមរក្សាកញ្ចប់ធាតុឪពុកម្តាយ និងគូសង្សារគាត់ ទុកលើធ្នើមុខកញ្ចប់ព្រះពុទ្ធរូប ដែលព្យួរនៅជញ្ជាំងក្បាលដំនេក ។

ព្រាត់ម្តាយ ព្រាត់ឪពុក ព្រាត់សង្សារគាប់ចិត្តធ្វើអោយលឹមក្រៀមក្រំ ធ្វើការមិនម៉ត់ចត់មាំទាំ ។ គាត់នៅផ្ទះមិនស្រនុក ដេកមិនលក់ដើរមិនសប្បាយ កញ្ចប់ធាតុលើក្បាលដំនេកបានដុតកំដៅគាត់អោយខឹងនឹងមេឃុំផាន់ និងបារាំង ជប៉ុន អោយខ្ពើម អោយស្អប់អំពើថោកទាបនៃសង្គ្រាមចក្រពត្តិប្លន់ប្រទេសជិះជាន់មនុស្ស ។

សេចក្តីសោកស្តាយនិងសេចក្តីក្រោធ បាននាំអោយលឹមនឹកឃើញពេលដែលគាត់ធ្លាប់រស់នៅជាមួយបុគ្គលដែលចាកស្ថានទៅ ។ វត្ថុទាំងប៉ុន្មាននៅក្នុងផ្ទះ ក្រោមផ្ទះ ក្រៅផ្ទះ ដូចជាមានវិញ្ញាណចេះនិយាយកំរើកចិត្តអោយឃើញអនុស្សាវរីយ៍ ។

ផ្គាក់ ដាវ លំពែង ដែលសៀតនៅជញ្ជាំងកណ្ដាល ដាស់លឹមអោយឃើញរឿងយប់មួយពេលក្មេងដេកលក់ មានចោរចង្រៃមកកំញើញឡើងប្លន់ផ្ទះគាត់ ។ យប់នោះតាង៉ែតគ្មានតក់ស្លុតកន្ត្រាក់លំពែងរត់ទៅទ្វារក្រោយ ហើយបានដោះចន្ទាស់បង្ហើបទ្វារឈរចាំចាក់ចោរ ។ នៅទ្វារមុខលឹមនិងយាយម៉ុកយាមចាំចោរ ។ លឹមកាន់ផ្គាក់ម៉ែគាត់កាន់ដាវ បើកទ្វារដោយក្លាហានស្រែកហៅចោរចង្រៃអោយឡើងផ្ទះ ។ ឃើញសេចក្ដីក្លាហាននៃម្ចាស់ផ្ទះដូចនេះ ចោរភ័យមិនហ៊ាននៅប្លន់បានដកខ្លួនរត់ទៅវិញបាត់ ។ អ្នកភូមិដឹងថាមានចោរប្លន់ ឆោឡោស្រែកហៅដាស់គ្នា ។ ខ្លះប្រដាប់លំពែង ខ្លះផ្គាក់ពូថៅ ខ្លះដាវ ខ្លះស្នា ចាត់គ្នាជាកងជាពួកដេញចោរពាលរត់ខ្ចាត់ខ្ចាយ ។ យប់នេះអ្នកភូមិស្រី ៗ និងក្មេង ៗ វេចបង្វិចសំពត់ ហិប ស្លា ផ្តិលទឹក កងក្រវិលមាសប្រាក់ចុះមកពួននៅកៀនជង្រុក ខ្លះដេកក្នុងទ្រុងគោ ។ ចំនែកប្រុស ៗ ចាត់គ្នាយាមគ្រប់មាត់ច្រក គ្រាប់ផ្លូវចូលភូមិឃ្លាំកុំអោយចោរចូលមកទៀត ។

ត្មោង ជន្លួញផ្ដៅលាបម្រ័ក្សណ៍ខ្មៅព្យួរនៅសសរទ្រូងល្វែងខាងក្រៅបានដាស់លឹមអោយឃើញរឿងវែងឆ្ងាយ ។ កាលនៅកុមារអាយុ ១២ ឆ្នាំ លឹមបានតាមម្ដាយគាត់ទៅកាត់ប្រហុកនៅច្បារអំពៅចុងស្ពានជ្រោយតាអោក ។ កុមារលឹមឃើញត្មោង ផ្ដៅនេះស្រលាញ់ពេញចិត្តចង់បានសូមទិញគេ ៗ មិនលក់អោយ ។ គេបបួលដូរនឹងអង្ករវិញ ។ លឹមមិនហ៊ានប្រាប់ម្ដាយគាត់លបលួចអង្ករពីកំប៉ុងទឹកដោះគោដូរយកត្មោងផ្ដៅ ។ ម្ដាយគាត់ជេរប្រទេចគាត់ជាខ្លាំងព្រោះខ្វះអង្ករដូរត្រីប្រហុក ។ មកដល់ផ្ទះ ឪគាត់បានបោះជន្លួញដែកគោលអោយ ។ បរទេះទៅណាមកណាលឹមយកត្រមោងនោះប្រើជានិច្ច ។

ហិបស្លាផ្តិលទឹក ចានចង្កៀងខ្លាញ់ មានរឿងនិយាយប្រាប់លឹមអោយឃើញពេលគាត់នៅជាមួយឪពុកម្ដាយគាត់ ។

លឹមមិនគ្រាន់តែព្រួយក្នុងការព្រាត់ឪពុក ម្ដាយគួសំលាញ់ទេ ។ គ្រាប់បែកអាមេរិចកាំងមិនគ្រាន់តែសំលាប់យាយម៉ុក តាង៉ែត នាងហេងទេ គ្រាប់បែកចក្រពត្តិបានសំលាប់គោគាត់បានកំទេចរទេះគាត់គ្មានសល់បន្តិច ។ លឹមចុះក្រ គ្មានរទេះ គ្មានគោប្រើ ។ តាង៉ែតបានខ្ចីបុលប្រាក់គេយកមកទិញស្រូវធ្វើអង្ករលក់ ។ បងគាត់បានចងការប្រាក់គេយកមកទិញស្រូវធ្វើអង្ករលក់ ។ បង់គាត់បានចងការប្រាក់ ពីអាចារ្យគឹមយកមកធ្វើបុណ្យបូជាខ្មោចឪពុកម្ដាយគាត់ ។

អាចារ្យគឹមវត្តជើងភូមិ ជាអ្នកចេះធម៌អាថ៌ បាលីគ្រាន់បើ ។ គាត់មានមេត្តាដល់ជីវិតសត្វ ។

គាត់មិនហ៊ានធ្វើអន្លង់ចាប់ត្រី ចិញ្ចឹមមាន់ ខ្វារក្តាម រកខ្យងដូចអ្នកភូមិខ្លះទេ ។ រាល់ថ្ងៃសីល គាត់ទៅវត្ត ហើយរាល់ព្រឹក គាត់បានដាក់បាត្រ ។ តាំងពីគាត់បានធ្វើអាចារ្យមក គាត់បានគ្មានសំចៃអង្គៀសប្រាក់សង់វិហារ សង់កុដិ ។ ល ។ គាត់បានទទួលសេចក្តីរាប់អានពីអ្នកភូមិគ្រប់គ្នា ហើយអុងប៉ាងថាវ ហ៊ាឡាំបាននាំកចិនធ្វើផ្កា ហើយបានទាំងសង់ខ្លោងទ្វារវត្តទៀតផង ។

ក្រៅពីឧបត្ថម្ភវត្ត អុងប៉ាងថាវ និងហ៊ាឡាំបានអោយលុយមកថៅកែចិនខ្មែរតូច ៗ បណ្តាក់ស្រូវ ស្ករ ។ ល ។ អាចារ្យគឹមក៏ត្រូវអុងប៉ាងថាវ និងហ៊ាឡាំ ផ្ញើរប្រាក់ទុកចងការអោយអ្នកភូមិដើមអំពិលដែរ ។ អ្នកភូមិណាខ្លះខាតអាចទៅខ្ចីពីអាចារ្យគឹម ហើយសងគាត់វិញជាស្រូវ ជាអង្ករ ជាស្ករ ជាស្រែជាគោ ជាកំលាំង ។ ល ។ ដោយវិធីប្រដាក់នេះ អុងប៉ាងថាវបានធ្វើជាថៅកែមួយធំនៅគោកចំបក់ ហើយអ្នកស្រុកម្តងមួយ ៗ បានធ្លាក់ខ្លួនទៅជាកូនបំនុលគាត់គ្រប់គ្នា ។

រាល់ថ្ងៃខែដាច់ អុងប៉ាងថាវ រឺ ហ៊ាឡាំបានមកវត្តជួបអាចារ្យ គឹមអោយកាន់បញ្ជីត្រឹមត្រូវ ហើយអោយខំទារប្រាក់បុលពីអ្នកជំពាក់ ។ និងអោយដាក់ផែនការ ទិញស្រូវ រឺ ប្រមូលស្ករកុំអោយអ្នកស្រែដឹកទៅលក់ឯភ្នំពេញទាន់ ។ អាចារ្យគឹមស្តាប់បង្គាប់អុងប៉ាងថាវគ្មានល្អៀង ។ ម្លោះហើយតែដល់រដូវច្រូត រដូវស្ករគាត់ខំដើរកាត់ភូមិ ទារពីអ្នកជំពាក់អោយអុងប៉ាងថាវ ។ ពិតមែនតែឃើញលឹមក្រគ្មានគោ គ្មានរទេះ ពិតមែនតែលឹមធ្វើស្រែមិនបាន អាចារ្យគឹមឃ្លាំងធម៌បានបង្ខំលឹមសងប្រាក់អុងប៉ាងថាវ ។ គាត់បានវែកញែកផ្លូវធម៌ ផ្លូវលោកប្រាប់លឹមថា ៖ " អន្ទិតឯងដឹងទេ ខ្មោចឪឯងបានយកលុយពីអញសន្យាថាសងជាស្រូវ បើគ្មានស្រូវសន្យាប្រគល់ស្រែថ្លុក ស្រែត្រពាំងដូចមានក្នុងសំបុត្រនេះស្រាប់ ។ អញដឹងថាឯងក្រដែរតែអុងប៉ាងគាត់មិនព្រមសោះ ។ ឯងត្រូវតែសងជូសគាត់ទៅ បើឯងមិនចង់អោយម៉ែឪឯងមានពៀរទៅជាតិក្រោយ ។ ឯងដឹងខ្លះហើយតាមផ្លូវធម៌បើអ្នកណាខ្ចីប្រាក់គេមិនសង អ្នកនោះត្រូវរងទុក្ខវេទនាទៅថ្ងៃក្រោយ ។ ឯចំនែកផ្លូវលោកវិញ គេត្រូវអូសស្រែ...។ ឯងកុំរឹងទទឹងអញមានសំបុត្រឪឯងស្រេច មានមេភូមិផាន់ជាសាក្សីស្រាប់ ។ សំបុត្រដីនៅឈ្មោះខ្មោចឪឯងទៀត ។ បើចង់ស្រួលឯងត្រូវប្រគល់ស្រែមក គង់ទៅដល់សាលាណាក៏វាមិនឈ្នះអុងប៉ាងថាវដែរ...។ ត្រូវរកលុយអោយបានមកបើមិនបានទេ អាទិត្យក្រោយនេះអុងប៉ាងថាវមកកាត់បញ្ជីនៅផ្ទះមេឃុំហើយ " ។

................................................

## ៩ សំបុត្រ

តាំងពីអុងប៉ាងថាវ អូសស្រែថ្លុក ស្រែត្រពាំងមក លឹមបានផ្លាស់របររកស៊ី ។ គាត់កាប់អុស រត់រ៉ឺម៉ក ជាន់អង្គរលក់ ។ គាត់ចុះឡើងព្រៃកន្ទោត ក្បាលថ្នល់ភ្នំពេញ ។ របរថ្មីបណ្តុះគំនិតថ្មី ។ ការរកស៊ីហាក់ចុះហាក់ឡើងគ្មានទីកំនត់ ស៊ីមិនឆ្អែត បានរុញអោយឃ្លាតពីភូមិដើមអំពិល ។ គំនិតប្តូរផ្តាច់លោះស្រែថ្លុក ស្រែត្រពាំង កេរខ្មោចម៉ែមកវិញបានរសាយ ។ មិនយូរប៉ុន្មាន គាត់ត្រូវលក់ដីភូមិអោយអុងប៉ាងថាវទៀត ។

មុនថ្ងៃប្រគល់ផ្ទះអោយអុងប៉ាងថាវ លឹមបានទៅលាលោកគ្រូសូត្រស្តាំវត្តត្បូងដែលជាគ្រូរបស់គាត់ ។ ពេលលឹមទៅលោកគ្រូត្រេចអរសួរថា ៖

អញបានផ្តាំតាមមេឃុំភូមិថាន់ អោយឯងមកជួបអញ ! ឯងដឹងទេ ?

ខ្ញុំព្រះករុណាមិនបានដឹងឡើយ ព្រោះរវល់ណាស់ ! បន្តិចក្បាលថ្នល់ បន្តិចព្រៃកន្ទោត...។ ហើយឥលូវលក់ផ្ទះអោយអុងប៉ាងថាវទៀត ខាតអស់២០០៖០០ ។ គាត់ដឹងថាឯងខ្វះគាត់ចេះតែវាយបន្ថោក...។

ឯងគិតទៅណា ?

ចេះតែដើរហើយ ! ទ្រាំនៅមិនបានស្រុកយើងនេះគ្មានស្រែធ្វើនោះ !

អញមានដំនឹងមួយប្រាប់ឯង ។ ឯងចាំទេឧបាសកខើចជើងនៅវត្តបាសក់ព្រះត្រពាំង ។ គាត់បានផ្ញើរសំបុត្រមកអញច្បាប់ ។ ឯងយកសំបុត្រនេះមើលចុះ ។

លោកគ្រូហុចសំបុតមកលឹម ។ បើកមើលឃើញសេចក្តីដូចតទៅ ៖

ភ្នំពេញ ថ្ងៃ ១ អាវរិល ១.៩៤៦

សូមថ្វាយបង្គំមកលោកបង

ខ្ញុំព្រះករុណាបានមកដល់ភ្នំពេញជិតពីរខែហើយ ។ ដោយរវល់ពេក ក៏មិនបានមជួបផ្ទាល់នឹងលោកបង ។ សូមផ្ញើរប្រគេនសំបុត្រនេះជាដំណើង ។

ដូចលោកបងបានជ្រាបហើយ ក្នុងពេលផាស៊ីសជប៉ុនចូលស្រុក ប្រជាជនខ្មែរទាំងមូលវេទនាតោយ៉ាកជាពន់ពេក ។ រាជការសៀមបានដណ្តើមយកខេត្តបាត់ដំបងពង្រាត់ខ្មែរអោយបែកគ្នា កូនព្រាត់ពីម៉ែឪ ប្អូនព្រាត់បង ប្រពន្ធបាត់ប្តី ។ ល ។

នៅក្នុងស្រុកកងទ័ពជប៉ុន បានចូលមកដេរដាសពាសពេញមកតំរួតលើកងទ័ពជប៉ុនបារាំងជញ្ជក់ឈាមញើសប្រជាជនខ្មែរ ។ រាជការពេលនោះបានបង្អត់អំបិល បង្អត់សំពត់ ។ ប្រជាជនដាំកប្បាសគ្មានអំនាចលក់ និងរវៃសំលីខ្លួនឯង ។ ភ្នាក់ងារថ្មី អ្នកចាប់កប្បាសបានដើររុករើលុកលុយឆែកឆេរចាប់លក់ពិន័យជាប្រាក់ រឺដាក់គុកដល់អ្នកត្បាញសំពត់គ្របដណ្តប់ខ្លួន ហើយមានកាប់កំទេចកំទីរហាត់ និងកីត្បាញ ។ រាស្ត្រគ្មានច្បាប់ត្បាញសំរាប់ប្រើខ្លួបឯង ប៉ុន្តែត្រូវទៅបើក សំលី គកប្បាស ពីសាលាស្រុកយកមករវៃត្បាញជាភ្នួយជូនរាជការវិញ ។ នារីត្បាញភាគច្រើនគ្មានបានថ្លៃឈ្នួលមួយសេន បានតែនឿយនឹងខាតពេលធ្វើស្រែចំការរបស់ខ្លួន ។

ក្នុងពេលនោះប្រជាជនខ្មែរ ស្ទើរគ្រប់គ្រួសារនៅគ្រប់តំបន់ក្នុងប្រទេសបានរុះបារដើម្បីនឹងបិទបាំងកេរខ្មាស ។ គ្រួសារខ្លះ មានសំពត់មួយបន្លាស់សំរាប់គ្នាបីនាក់ រឺបួននាក់ ។ បើប្រពន្ធនៅផ្ទះប្តីស្លៀកសំពត់ចេញទៅធ្វើការក្រៅផ្ទះ ។

ឯចំនែកផាស៊ីសជប៉ុនវិញ បានបង្ខំចាប់កេណ្ឌគូលីទៅធ្វើជួសជុលកន្លែងចំនតយន្តហោះដើម្បីធ្វើសង្គ្រាមផាស៊ីសមហាអាស៊ី ។ ប្រជាជនខ្មែរទាំងស្រីទាំងប្រុសបានត្រូវពួកសិកបារាំងជប៉ុនទុកដូចជារ៉ូងគោក្របី ត្រូវគេប្រើគ្មានដឹងយប់ថ្ងៃ ត្រូវគេកៀរចាប់យកទៅឆ្ងាយពីទីលំនៅរបស់ខ្លួន ។

លុះមកដល់ខែអុកតូប្រ៍ឆ្នាំទៅ កំលាំងប្រជាធិបតេយ្យ ក៏បានមានជ័យជនះលើពួកផាស៊ីសនៅគ្រប់សមរភូមិ ។ ប្រទេសខ្មែរយើងក៏ត្រូវរួចផុតពីក្រញាំផាស៊ីសជប៉ុនដែរ ។ តែសេចក្តីត្រេចអររបស់យើងមិនស្ថិតស្ថេរឡើយ ។

តាំងពីផាស៊ីសជប៉ុនបរាជ័យទៅនៅស្រុកយៀកណាមខាងត្បូង អាណានិគមនិយមបារាំងបាននាំទ័ពចូលមកប្លន់វិញ ។ ប្រជាជនយៀកណាមបានក្រោកឡើងតស៊ូយ៉ាងអង់អាចទល់នឹងពួកទមិឡបារាំង ។ ទាំងក្មេងទាំងចាស់ ទាំងស្រី ទាំប្រុសខ្លះប្រដាប់លំពែង ខ្លះពីងពង់ឬស្សីបានមូលគ្នាដូចខ្លួនមួយក្រោកឡើងវាយខ្មាំងបារាំងគ្រប់តំបន់ ។

ខ្មាំងបារាំងបានឆ្លងមកប្រទេសយើង ។ ដូចលោកបងបានជ្រាបហើយ វាចូលមកត្រួតគ្រប់

ក្រសួងរាជការវិញ ហើយវាបានចាប់ផ្ដើមចាប់ចងសំលាប់ប្រជាជនយើង ។ តែនៅមុខស្ថានការណ៍នេះ ប្រជាជនយើងមិនសុខចិត្តនៅធ្វើខ្ញុំបារាំងទៀតឡើយ ។ ប្រជាជនយើង បានក្រោកឡើងគ្រប់ជាន់ថ្នាក់តស៊ូវិញ ។ ការតស៊ូយើងលើកនេះវេទនាពីបាក ប៉ុន្តែយើងប្រាកដជាឈានទៅរកជ័យជំនះ ។ យើងត្រូវរួបរួមសាមគ្គីប្រជាជនយើងទាំងមូលនឹងត្រូវចងមិត្តជាមួយប្រជាជនវៀតណាម ឡាវ ដែលក្រោកវាយបារាំង ។

ចុងបំផុតសូមលោកបងអោយដំនឹងមកខ្ញុំព្រះករុណាផង តើនេនលឹមកូនសិស្សលោកបងនៅឯណា ? សឹក រឺ នៅ ? មានប្រពន្ធ រឺ នៅ ? សូមលោកបងប្រាប់អោយមកជួបនឹងខ្ញុំព្រះករុណាយ៉ាងប្រញាប់ ។

សូមលោកបងទទួលសេចក្ដីគោរពពីខ្ញុំព្រះករុណា ។

យឹម

លុះមើលចប់ លឹមបានប្រគេនសំបុត្រទៅលោកគ្រូ ។ បានសួរថា ៖

ឯងយល់ដូចម្ដេចសំបុត្រនេះ ? ឯងត្រូវទៅជួបយឹម ។ ឯងមុខជាដឹងរឿងរ៉ាវច្រើនទៀត ។ ឯងស្គាល់យឹមជាក់លាក់ទេ ?

... ស្គាល់ជាក់លាក់ណាស់ ។ ខ្ញុំព្រះករុណាហៅគាត់តែលោកគ្រូ ។ ហើយកុំតែជាប់ម៉ែឪចាស់ ៗ កុំអីមិនត្រលប់មកភូមិវិញទេ នៅជាមួយគាត់ឯបាស័កព្រះត្រពាំងរហូតស្រេច...។

យឹមពីដើមឈ្មោះរឿង ។ លោកគ្រូបានកាត់ ។ គាត់បានរៀនសាលាបារាំងដល់ថ្នាក់លេខមួយ រួចបានចូលធ្វើទាហានជើងក្រហមទៅច្បាំងស្រុកបារាំង នៅសង្គ្រាម ១.៩១៤ ១៨ ។ ក្រោយសង្គ្រាម យឹមបានលាចេញពីកងទ័ព ហើយបានចូលធ្វើកម្មករនៅប្រទេសបារាំង ។ គាត់បានរស់នៅស្រុកបារាំងបាន ៤ ៥ ឆ្នាំដែរ ហើយសរសើរស្មារតីសេរីភាពនឹងសមភាពប្រជាជនបារាំង ។ មកដល់ស្រុកខ្មែររបស់យើងវិញបានជាងពីរឆ្នាំយឹមត្រូវរាជការចាប់អោយធ្វើទាហានជើងក្រហមម្ដងទៀតពាក់ដោយ ។ កាលប្រជាជនយៀកណាមបះវាយបារាំងនៅកូសាំងស៊ីន បារាំងបានកេណ្ឌ

ខ្មែរអោយទៅបង្ក្រាប ។ យឹមត្រូវបារាំងបញ្ជូនទៅដែរ ។ អំពីឃោរឃៅរបស់កងទ័ពអាណានិគម បារាំងធ្វើអោយយឹមប្រឆាំងវិញជាច្រើន ។ មិនគ្រាន់តែមិនចាប់ធ្វើបាបប្រជាជនដូចទាហានបារាំងដែលច្រើនចាប់ស្រី កូនក្រមុំ សំលាប់កូនក្មេង ប្លន់យក មាសប្រាក់ យឹមបានជួយឧបត្ថម្ភដល់ប្រជាជនស្រុកស្រែចំការទៅវិញ ។ គាត់ទៅដល់មុនបារាំង កាលណាគាត់បានបើកផ្លូវអោយប្រជាជនរត់គេចយកទ្រព្យធនធានទៅលាក់ ។ យឹមធ្វើរបៀបនេះមិនបានយូរទេ ។ ក្រោយមកបារាំងវាពិនិត្យដឹង យឹមដឹងខ្លួនក៏បាននាំពួកគាត់រត់ តែបារាំងតាមបាញ់ខ្ចាត់ខ្ចាយ ។ យឹមម្នាក់ឯងបានគេចរួចហើយត្រូវរបួសយ៉ាងខ្លាំងនៅជើងឆ្វេង ។ ហេតុនេះហើយបានជាគាត់ដើរខ្ញើច ៗ ។ បារាំងរកគាត់មិនឃើញក៏បានលប់ឈ្មោះថាស្លាប់ ។ ក្រោយពីនេះយឹមបានទាក់ទងជាមួយអ្នកតស៊ូយៀកណាមជាច្រើននាក់ហើយគាត់ក៏បានប្រែឈ្មោះ លាក់ខ្លួនពួននៅបាស័កព្រះត្រពាំង ។ គាត់គ្មានទីលំនៅនឹងទេ ។ គាត់ផ្លាស់ឈ្មោះញឹកណាស់ ។ គាត់ជាមនុស្សល្អយុត្តិធម៌ពិត ។

ខ្ញុំព្រះករុណាស្គាល់តំលៃគាត់ពិតហើយ ។ កន្លះឆ្នាំនៅជាមួយគាត់ ខ្ញុំព្រះករុណាបាយល់ដឹងស្គាល់រឿងការបដិវត្តស្រុកធំ ៗ ...។

យឹមជាអ្នកចូលចិត្តដាស់ប្រជាជនណាស់ ។ ឯងត្រូវទៅជួបគាត់កុំខាន ។

ខ្ញុំព្រះករុណាចូលចិត្តណាស់ ។ គាត់សំនាក់នៅកន្លែងណាភ្នំពេញ ...។

គាត់សំនាក់ផ្ទះលោក ដួង នៅក្រោយវត្តបូទុមខាងជើងស្រះក្រោយជំនាក់មួយសង់ថ្មី ។ ឯងស្គាល់គាត់ហើយ មិនចាំបាច់យកសំបុត្រពីអញទេ ។

មិនចាំបាច់សំបុត្រទេ ។ ខ្ញុំព្រះករុណាស្គាល់គាត់ហើយ ។ តែខ្ញុំព្រះករុណាមកនេះមានបំនងមួយ ។ មុននឹងចេញពីភូមិយើងទៅ ខ្ញុំព្រះករុណាសូមផ្ញើធាតុបីនឹងព្រះអង្គលោកគ្រូផង...។

ថារួចលឹមប្រគេនធាតុបីកញ្ចប់ទៅលោកគ្រូ លោកគ្រូហៅក្មេងយកទៅដាក់ក្នុងទូ ។ បន្ទាប់លោកមានពុទ្ធដីកា ៖

អន្ទិតឯងកុំអាលទៅណាវិញ ។ អញមានកិច្ចច្រើនផ្តាំផ្ញើឯងទៀត...។

....................................

# ១០ លាភូមិកំណើត

ព្រឹកថ្ងៃបន្ទាប់ថ្វាយបង្គំលាលោកគ្រូ ពេលថ្ងៃកំពស់ចុងឈើ នៅផ្ទះលឹមមានមនុស្សក្មេងចាស់មកជុំ ។ ពូស្វាយនិងមីពតបានមកជូនដំនើរអោយពរថា ៖

ទៅអោយបានសុខសប្បាយ ! រកស៊ីអោយប្រកប ឈ្នះមារសត្រូវ ! អើត ៗ ភូមិដើមអំពិលផង ! កុំចោលយូរពេក ! ។

តាមុយពិតតែនៅរហូតចុងភូមិខាងត្បូងក៏ខំឆ្លៀតមកជូនដំនើរផ្តាំផ្ញើរលឹមដែរ ។

ទៅខំរកស៊ីអោយមែនទែន ។ សន្សំលុយអោយបានច្រើនមកជាវ ថ្លុកស្រែត្រពាំងខ្មោចម៉ែឪឯងវិញ ។

អាចារ្យគឹមបានមកសូមទោសលឹមថា ៖ ពូខំនិយាយអុងប៉ាងថាវកុំអោយអូសស្រែឯងដែរតែគាត់មិនស្តាប់ ។ គាត់ប្រាប់ពូថា អោយឯងនៅផ្ទះនេះមួយខែទៀត ចុះគាត់មិនទាន់ដាក់ស្រូវភ្លាមទេ ។ ពូគ្មានអ្វីអោយឯងទេ ។ ពូបានតែក្រមាមួយនេះដែលមីងឯងទើបតែនឹងកាត់ពីកីម្សិលមិញអោយ ។ ហ៊ុយកទៅគ្រាន់នឹងដណ្តប់ផ្លាស់ងូតទឹក ។ កុំខឹងនឹងពូថាពូមិនជួយអ្នកភូមិយើងអោយសោះ ។

អ្នកយិនប្រពន្ធខ្មោចអន្ទិតអិនក៏បានមកតំអូញដែរ ។ រងកម្មមែនគូលីជប៉ុន ព្រាត់ប្រាសអស់ហើយ ។

លឹមមុខស្រងូតបានលាអ្នកមកជូន ។ គាត់លើអង្គរហើយកណ្តៀតបង្វេចមួយ ដើរចេញទៅជើងសំដៅទៅថ្នល់ខាងលិចភូមិចាំរទេះសេះ ។ ក្មេង ៗ រត់ស្រែតាមគាត់ ខ្លះជួយកាន់បង្វិច ខ្លះទៀតដណ្តើមថង់អង្ករ ។ មីងពត និងមីងអ៊ូប្រពន្ធអាចារ្យគឹម បានជូនមកថ្នល់ដែរ ។

កន្លះម៉ោងក្រោយរទេះសេះដឹកជ្រូកមួយមកពីត្បូងលឹមហៅជិះ ។ អ្នកជូនដំនើរបានស្រែកអោយពរម្តងទៀត ៖

ទៅអោយសុខសប្បាយ ! កុំភ្លេចភូមិយើង ! ឆាប់មកវិញ ។

លឹមបានអើតពីរទេះសេះលើកដៃស្រែកមកវិញ ៖ លាហើយសូមនៅអោយបានសុខសប្បាយ ។

រទេះសេះបរមកដើងដល់ក្បាលថ្នល់ ព្រែកឬស្សី ព្រៃត្នោត ស្ពានជ្រោយតាអោក...។ មកដល់ស្ពានកូនកាត់លឹមចុះពីរទេះ ដើរសំដៅទៅក្រោយវត្តបូទុមជ្រុងខាងជើងជាប់ស្រះក្នុងជំនាក់មួយសង់ថ្មីសួររក ផ្ទះលោកដួង ។ ឡើងចូលទៅក្នុងផ្ទះឈ្នួលមួយក្នុងរបងជំនាក់ លឹមបានឃើញឧបាសកខើចជើងអង្គុយនៅកំពុងតែមើលសៀវភៅម្នាក់ឯង ។ លឹមបានគួរសមជំរាបសួរ

សុខសប្បាយទេ ! ភ្លេចខ្ញុំហើយ រឺនៅលោកគ្រូ ?

បាទសុខសប្បាយទេ ! អញ្ជើញមកមានការអ្វី ?

ខ្ញុំឈ្មោះលឹមកូនសិស្សលោកគ្រូម៉ក់...។

អញ្ជើញអង្គុយមក ។ ម៉េចសុខសប្បាយទេ ? ។ លោកបងបានស្រួលព្រះអង្គទេ ខ្ញុំទន្ទឹងមើលតែផ្លូវប្អូន...។

លឹមបាននិយាយប្រាប់ភេទការណ៍ ក្នុងគ្រួសាររបស់គាត់ ។ យឹមបានជួយរំលែកទុក្ខ ហើយបានលួងលោមថា ៖

ការព្រាត់ប្រាស់នេះ គឺបណ្តាលមកពីសង្គ្រាមចក្រពត្តិ ។ បើកចង់ស្រួលចង់សុខទាល់តែយើងប្រឹង ។ ខ្ញុំចង់ពឹងប្អូនបន្តិច ។

ដល់ឃ្លានេះ យឹមឈប់និយាយ ។ គាត់អើតមើលឆ្វេងស្តាំចោលភ្នែកមើលនាឡិកាឃើញម៉ោង ១០ កន្លះ ។ បន្ទាប់មកគាត់និយាយ ត ៖

ខ្ញុំមានពេលខ្លីណាស់ថ្ងៃនេះ...។ ណ្ហើយខ្ញុំជំរាបអោយដឹងហើយទៅចុះ សូមប្អូនកុំប្រាប់នរណាអោយសោះ ។ ខ្ញុំចង់ពឹងប្អូនបន្តិច...។

ការធ្ងន់ រឺ ស្រាល ?

ប្អូនដឹងស្រាប់ហើយ លោកបងម៉ក់បានប្រាប់ប្អូនសព្វគ្រប់ហើយ បានជាអោយលោកប្អូនមក ។ ផ្ទះនេះមិនមែនជាផ្ទះខ្ញុំទេ ម្ចាស់ផ្ទះបានត្រូវជាប់ឃុំនៅគុក ហើយមួយខែទៀតនឹងត្រូវកាត់

ទោស ។ ដូងបានអោយដំនឹងមកតាមប្អូនម៉ឹងគាត់ថា ត្រូវតែរត់ចេញពីគុក ដើម្បីទៅរកគ្នាវាយបារាំង ។ ម៉ឹងប្អូនដូងទៅផងមិនទាន់បាន ព្រោះត្រូវអោយនៅរៀនទៀត ។ ខ្ញុំយល់ថាប្អូនបំពេញកិច្ចនេះបាន ។ ជាខ្ញុំផ្ញើរសំបុត្រហៅប្អូនមក តើប្អូនជូនដូងទៅស្វាយដូនកែវបាន រឺ ទេ ...។

ខ្ញុំមិនប្រសប់ទេ តែត្រេកអរនឹងបំពេញភារៈនេះ ។

ប្អូនជូនដល់ស្វាយដូនកែវត្រលប់វិញចុះ...

ខ្ញុំមិនត្រលប់វិញទេ ទៅរហូតជាមួយហើយ...។

ស្រេចតែជជែកគ្នាទៅថ្ងៃក្រោយចុះ ។ បើប្អូនយល់ព្រមដល់ថ្ងៃអាទិត្យពេលព្រឹកចូរប្អូនជួបម៉ឹងទាក់ទងជាមួយគ្នារកថ្នាំសង្កូវលុយកាក់ និងរើសថ្ងៃអោយបានស្រួល...

បាទ !

ម្យ៉ាងទៀតត្រូវរក្សាសំងាត់អោយមែនទែន កុំអោយបែកការ ខ្ញុំមួយអាទិត្យទៀត ក៏ត្រលប់ទៅស្រុកក្រោមវិញ ។

និយាយដល់ត្រង់នេះ នាឡិកាភ្លេងព្យួរនៅជញ្ជាំងបានទូងប្រាប់ថាម៉ោងដប់មួយខ្វះប្រាំ ។

យឹមក្រោកពាក់អាវស្លៀកខោបណ្ដើរនិយាយបណ្ដើរ ៖

ខ្ញុំស្ដាយណាស់ដោយពុំបាននៅជជែកយូរ ។ ខ្ញុំត្រូវខានមិនបានជួបបងខ្ញុំនៅផ្សារកាប់គោម៉ោង ១១ នេះ ប្អូនឯងនៅសំនាក់ឯណា ?

ខ្ញុំសំនាក់នៅវត្តលង្កា ។

បើដូចនោះអញ្ជើញទៅសិនចុះ ។ ដល់ស្អែកព្រឹកថ្ងៃអាទិត្យមកជួបប្អូនម៉ឹងនៅកន្លែងនេះ ។ សូមប្អូនកុំអោយបែកការអោយសោះ ។

ថាចប់យឹមនិងលឹមចេញពីផ្ទះហើយ អ្នកទាំងពីរក៏បានលាគ្នា...។

....................................

# ១១ ផ្លូវថ្មី

ក្រោយខ្មាំងបារាំងចូលមកប្លន់ប្រទេសយើងវិញ ប្រជាជនខ្មែរយើងគ្រប់ជាប់ថ្នាក់ហើយ សំខាន់ប្រជាជនកសិករស្រីប្រុស ក្មេងចាស់បានក្រោកឡើងគ្រប់តំបន់ ។ នាម៉ឺន អ្នកជំនួញ សិស្សានុសិស្ស ព្រះសង្ឃ បានគ្រប់វិធីប្រឆាំង នឹងការជិះជាន់នៃខ្មាំងបារាំង ។

ពិតមែនតែពួកអាណានិគមនិយមបារាំង នឹងជ្រៀតជ្រែកចក្រពត្តិអាមេរិចកាំងបានប្រើកល ល្បិចល្បួងកំហែងដុតសំលាប់យ៉ាងឃោរឃៅ កំលាំងប្រជាជនខ្មែរបានរីកធំជាលំដាប់នៅគ្រប់ខេត្ត ក្នុងប្រទេស ។ ប្រជាជនបានជួយឧបត្ថម្ភគ្រប់ផ្លូវ ខ្លះអោយកូនទៅតស៊ូ ខ្លះជួយប្រាក់ជួយអង្ករ ខ្លះ ជួយថ្នាំ ខ្លះជួយបន់ព្រះអោយឈ្នះ ។ ល ។

ក្រោយដែល លឹម ជូនដូងទៅស្វាយដូនកែវបានប្រហែលជិតប្រាំឆ្នាំ ម៉ឹងបានប្រលងជាប់ ចេញពីវិទ្យាល័យ ហើយបានធ្វើការក្នុងរាជការ ។ នៅខែត្រព្រៃវែង ម៉ឹងបានស្គាល់គ្រួសារអ្នកពេទ្យ ណារី ។ គ្រួសារនេះបានរាប់អានម៉ឹងដូចសាច់ញាតិ ។ អ្នកគ្រូ គូ រស់ ប្អូនជីដូនមួយអ្នកពេទ្យណារី បានរាប់អានម៉ឹងយ៉ាងស្មោះត្រង់ហើយជិតស្និទ្ធ ។ ស្ទើររាល់ថ្ងៃអាទិត្យ រឺ ថ្ងៃបុណ្យ គ្រួសារ គូរស់ បានបបួលម៉ឹងទៅជួបជុំ បាយទឹក រឺ បបួលគ្នាដើរលេង ។

ល្ងាចអាទិត្យមួយខែចែត្រ ម៉ឹងនិងអ្នកគ្រូ គូរស់ អ្នកពេទ្យណារី និងគ្នាច្រើនទៀតបាននាំគ្នា ចុះទៅដើរលេងវាលប្រាំង ដើរយកខ្យល់អាកាស រកទិញចាប ។ អ្នកគ្រូគូ រស់ និងម៉ឹងបានជជែកគ្នា ជក់មាត់សើចយ៉ាងរីករាយ ខ្យល់អាកាសបានផាត់ច្រានអ្នកទាំងពីរអោយឃ្លាតឆ្ងាយដាច់ពីគេ ។ អ្នកគ្រូគូ រស់ បានផ្ដើមសួរថា ៖

ម៉ឹងឯងរៀនជំនាន់ណា ?

រៀនជំនាន់គូ រស់ឯង ។ យើងប្រលងសេហ្វទីហ្វីការធំ បន្ទប់ជាមួយគ្នា ។ ខ្ញុំបានខ្ចីក្រដាស ផ្តិត គូ រស់ឯងផង ហើយទាំងខំប្រឹងប្រជ្រៀតគេឯងជួយមើលឈ្មោះអោយ គូ រស់ ឯងទៀត...។

អរគុណហើយដែលបានជួយខំមើលឈ្មោះខ្ញុំនោះ ។ ចុះនៅវិទ្យាល័យពួនជ្រកកន្លែងណា ក៏ខ្ញុំមិនដែលប្រទះមុខម្ដងសោះ ។

ធម្មតាស្រី ៗ នៅវិទ្យាល័យស្គាល់រាបអាននិយាយរក តែអ្នករៀនពូកែ សូត្រមេរៀនបារាំង និងកូនលោកធំ ៗ អ្នករៀនខ្សោយកាន់កន្ទុយគេ ៗ មិនស្គាល់ទេ... ។

និយាយមិនត្រូវទេ ។ ក្រែងតែគេ ឯខ្ញុំ ៗ មិនប្រកាន់អ្នកខ្សោយ អ្នកពូកែឡើយ...។ ឈ្លើយ ឈប់និយាយពីរឿងនៅវិទ្យាល័យទៅ ។ ឥលូវ ម៉ឹងឯងមិនគិតរកគូស្រករទេ រឺ ?

អ្នកបងពេជ្រណារី បានប្រាប់ខ្ញុំថា ម៉ឹងឯងឧស្សាហ៍ទៅលេងផ្ទះលោកចៅហ្វាយណាស់ ។ ម៉េចពេញចិត្ត អាមុំ រឺ សុវណ្ណា ស្រលាញ់ណាមួយប្រាប់ខ្ញុំ ចូលចិត្តអាមុំកូនលោក រឺ សុវណ្ណាក្មួយលោក ។ បើមិនហ៊ាននិយាយខ្ញុំជួយ ។ ខ្ញុំតែពេញចិត្តនរណាហើយខ្ញុំជួយទាល់តែសំរេច...។

ខ្ញុំគ្មានគិតដូច គូ រស់ ឯងស្មានទេ ។ រឿងផ្ទះសំបែងស្រេច ម៉ែ ឪទុកដាក់ចុះ...។

ចង់អស់សំនើចណាស់ ស្រេចលើម៉ែឪ ! ខ្ញុំខុសម៉ឹងឯងស្រលះ ។ ខ្ញុំបើចូលចិត្តនរណា ខ្ញុំប្រាប់ម៉ែឪភ្លាម ។ តែម៉ឹងឯងអាល័យគិតតែផ្កាយលើមេឃ...។ ត្រូវចេះមើលផ្កាជិតខាងក្នុងរបងជាមួយផង ។

រាល់ព្រឹក ខ្ញុំបានបេះផ្កាម្លិះក្នុងរបងយើង ។ គូ រស់ ឯងមិនឃើញ រឺ ? ដែលឃើញខ្ញុំមើលផ្កាយស្រែកយំរកព្រះច័ន្ទអណ្តែតអណ្តូងពីអង្កាល់ ? បើខ្ញុំហៅរក ខ្ញុំហៅ គូ រស់ ឯងចំ ៗ តែម្តង...។

នេះបានចំ ! គ្មានចេះទាល់សោះតែម្តង ។ គ្មាននរណានិយាយឈ្មោះម៉ឹងឯងទេ ។ ខ្ញុំដើរលេងរាល់ល្ងាចជាមួយក៏មិនធុញដែរ...។ អាមុំចិត្តគេមិនដូចយើងទេ ។ គេមិនអើពើនយោបាយទេ គំនិតគេ ឆ្ងាយពីយើងណាស់ កុំទៅលេងនឹងគេញឹកពេក ។

ម៉ឹងបានមើលមុខអ្នកគ្រូ គូ រស់ គ្មានចេញស្តី ហើយបន្តដំនើរទៅមុខទៀត ។ បន្ទាប់មកអ្នកគ្រូហុចបារីទៅម៉ឹងនិយាយថា ៖

កាលពីថ្ងៃ ព្រហស្បត៏ ខ្ញុំស៊ីលៀងផ្លាស់លោកគ្រូសារ៉ុម ។ គេអោយបារី ខ្ញុំមិនជក់ ខ្ញុំនឹកឃើញម៉ឹងឯងក៏ទុកយកមកអោយ ខ្ញុំដាក់ជាមួយផ្កាម្លិះ ក្រអូបទេ...។

ក្រអូប ! ។ ម៉ឹងបានឆ្លើយហើយដើរបៃបគិតអ្វីផ្សេង ៗ ។ មួយស្របក់ក្រោយម៉ឹងបាននិយាយ ៖

គូ រស់ លីស្នូរកាណុងទេ ! ឃ្លើល ៗ រាល់នាទីតែម្តង ។ គេបាញ់គ្នានៅឯណា ! ប្រហែល

បាញ់គ្នានៅព្រំដែនព្រៃវែងទេ រឺ លឺថាភ្នំពេញដំរីជាសំបុកខ្មែរឥស្សរៈ ។ ខ្ញុំលឺថាពួកវាមានពេងចក្រ ផងនៅព្រំដែន ហើយលឺថាពួកបារាំងចូលមិនចុះទេ ។ ពីអាទិត្យមុន លឺថាកងទ័ពពោធិកំបោបាន ចូលមកដល់បន្ទាយព្រៃនគរដែលជាបន្ទាយស៊ីវត្ថា កាលបះវាយបារាំងជាន់មុន ។

ម៉ឹងឯងចូលចិត្តនិយាយរឿងឆ្ងាយណាស់...។ ខ្ញុំមិនចង់គិតរឿងអស់ទាំងនេះទេ តែនឹករឿង នេះពិបាកណាស់ ។ លឺថាគេជិតចាប់ទាហានផង រឺ ...។

ខ្ញុំបានដឹងថាបារាំងនិងអាមេរិចកាំង បានបង្ខំប៉ៅដាយអោយចេញច្បាប់ចាប់កូនវៀតណាម អោយចូលធ្វើទាហាន ។ ត្រង់ស្រុកខ្មែរយើងមិនទាន់ឃើញច្បាប់នៅឡើយ ហើយមិនដឹងថាបារាំង អាមេរិចកាំងដាក់ស្មៀតដូចស្រុកវៀតណាម រឺមួយទៀតក៏ដាក់ស្មៀតបោកបន្លំយ៉ាងណាទេ...។

វីរហើយបើដូចនោះអស់បានសុខហើយ បំនងយើងពីរនាក់យ៉ាងណាទៅ ?

បំនងអ្វី ?

ស្អប់តែធ្វើពើទៀត ! នៅតែមិនព្រមយល់ ។ បើមិនយល់ក៏ហីចុះ គេនិយាយថាម៉ឹងឯងជា មនុស្សត្រឹមត្រូវស្លូតហើយហ្នឹងណាស់ ។ ពូប្លុងតុងហ៊ឹមបានមកលេងផ្ទះខ្ញុំអាទិត្យមុននិយាយប្រាប់ ខ្ញុំថា ម៉ឹងឯងល្អនឹងអ្នកធ្វើការជាមួយណាស់ ហើយចេះការពារមិនអោយបារាំងរំលោភលើ ។ អ្នកធ្វើ ការនៅក្រសួងម៉ឹងឯង វៀតណាមក៏ដូចខ្មែរសរសើម៉ឹងឯងណាស់...។ គេបន់អោយតែម៉ឹងឯងឡើង ធ្វើនាយក្រសួងនៅខេត្តនេះដល់បារាំងទៅស្រុក ។

ខ្ញុំមិនសប្បាយនឹងធ្វើការទេ ។ គ្រាន់តែដើរទៅត្រង់ណាក៏មានពួកគិញដើរតាមដែរ ។ កាល ពីអាទិត្យមុន បារាំងចៅហ្វាខ្ញុំហៅខ្ញុំទៅកិនបន្ទោសថា ខ្ញុំមិនចេះធ្វើការ ។ ខ្ញុំបានឆ្លើយតបទៅវិញថា បើខ្ញុំគ្មានសម្ថភាពដេញខ្ញុំចោលទៅ ខ្ញុំមិនអង្វរទេ ។ បារាំងមើលមុខហើយសួរខ្ញុំថា ៖ ចង់ជាប់គុក ទេ ។ ខ្ញុំបានសួរវិញថា ៖ ខ្ញុំមានទោសអ្វី ។ បារាំងនៅស្ងៀម ។ មួយស្របក់ក្រោយគាត់ប្រាប់ខ្ញុំថា ៖ បើចង់សុខត្រូវចេញពីស្រុកខ្មែរព្រោះគិញប៉ងចាប់ ។ ធ្វើនយោបាយមិនបានទេនៅស្រុកខ្មែរមិនដូច ស្រុកបារាំងឡើយ ។ អាទិត្យមុន ខ្ញុំបានដាក់ពាក្យមួយសូមផ្លាស់ទៅភ្នំពេញប៉ុន្តែបារាំងមិនបាន ឆ្លើយ...។

ខ្ញុំមិនចង់អោយម៉ឹងឯង ផ្លាស់ទេ ។

នៅទីនេះយូរទៀតមិនបាន ។ ខំៗ មានរឿងធំជាប់គុកឥតប្រយោជន៍...។

ម៉ឹងឯងមិនធុញទ្រាន់នឹងផ្ទះសព្វថ្ងៃ រឺ ? អ្នកបងពេជ្រ ណារី គាត់ចិត្តបានណាស់ ។ ពិតមែនតែគាត់មិនទាន់មានផ្ទះសំបែង តែគាត់ស្គាល់ចិត្តថ្លើមយើងណាស់ ។ គាត់ទុកម៉ឹងឯងដូចប្អូនបង្កើត...។

នៅក្នុងពួកបារាំងខូចខ្លួន ។ ឃើញតែបៀ ឃើញតែសំនូក ឃើញតែស្រា ឃើញតែស្រី ឃើញតែយសសក្តិ៍ ឃើញតែត្បូងទាំងគ្រាប់...។ យ៉ាងយូរមួយអាទិត្យទៀតខ្ញុំផ្លាស់ហើយ ។ តែខ្ញុំមិនភ្លេចចិត្តថ្លើម គូ រស់ ឯងចំពោះខ្ញុំទេ ។ ខ្ញុំកត់ទុកមិនភ្លេច ។

ឃ្មើល ! ស្នូរកាណុងញាប់រន្ថាន់ បានបង្អាក់ម៉ឹងអោយឈប់និយាយ ។ ម៉ឹងផ្ទៀងត្រចៀកស្តាប់ ហើយចាប់និយាយ ត ៖

ថ្ងៃនេះកាណុងបាញ់ញាប់តែម្តង... ។ តែលឺស្នូរកាណុង ខ្ញុំនឹងដល់បងខ្ញុំណាស់ ។ កាលខ្ញុំនៅវិទ្យាល័យ បងដូងបានជាប់គុក ។ គាត់បានរត់ចេញពីគុក ។ តាំងពីនោះមកខ្ញុំមិនដែលបានដំនឹងពីគាត់ម្តងសោះ ។ ខ្លះថាគាត់ធ្វើឥស្សរះ ខ្លះថាស្លាប់ ! ខ្លះថានៅសៀម ! ឱកាសណានឹងបានជួបគាត់ !

ខ្ញុំលឺថាឈ្មោះ នូ ដូង ធ្វើមេឥស្សរះ តំបន់កញ្ជ្រោចហ្នឹង រឺ បងម៉ឹងឯង ?

ប្រហែលជាគិញបារាំងបានដឹងថា បងខ្ញុំនៅតំបន់នេះហើយមើលទៅ បានជាបារាំងចៅហ្វាខ្ញុំប្រាប់អោយខ្ញុំចេញពីស្រុកខ្មែរកុំនៅនាំមានគ្រោះថ្នាក់ ។

និយាយដល់ត្រឹមនេះម៉ឹងឈប់ ។ គាត់ហូតកូនក្រដាស់ទក់មួយមើលមានសេចក្តីថា ៖

មកដល់ប្អូនសំលាញ់ !

បងមានសេចក្តីត្រេកអរដោយដឹងថា ប្អូននៅជិតបងជាពន់ពេក ហើយបានដឹងថាប្អូនសុខសប្បាយជាទេ ។ ឯចំនែកបងវិញ បានចេញពីប្រទេសសៀមហើយឆ្លងមកដល់តំបន់បូព៌ាទិសនេះបួនខែហើយ ។ ប្រទេសសៀមចង្អៀតណាស់ ព្រោះចក្រពត្តិអាមេរិចកាន់កាប់ ។

ការតស៊ូរបស់ប្រជាជនយើង បានកើនរីកធំនៅគ្រប់ខែត្រ តែការបុករុករបស់ខ្មាំងក៏កាន់តែខ្លាំងឡើងដែរ ។ អាណានិគមនិយបារាំងនឹងជ្រៀតជ្រែកអាមេរិចកាំងបានចាត់តាំងពួកចោរជា

ច្រើនក្រុមអោយក្លែងខ្លួនថាជាពួកតស៊ូ ។

ការតស៊ូរបស់យើងពិបាកវេទនាយូរអង្វែង ប៉ុន្តែប្រាកដជាមានជ័យជំនះ ។

ចុះបំផុតជំរាបម៉ែ ឪ ព្រមទាំងមាមីងបង ៗ ទាំងអស់គ្នាផងថា បងបានសេចក្តីសុខសប្បាយជាទេ ហើយទាល់តែបានសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យបានត្រលប់មកវិញ ។

បងលាហើយ

ដួង

មើលសំបុត្រនេះចប់ ម៉ឹងបត់ទុកវិញដើរគ្មានស្តី ។ អ្នកគ្រូ គូ រស់ បានសួរ ៖

ម៉ឹងឯងមានរឿងអ្វី ? ខ្ញុំជ្រុលសំដីទៅលើ រឺ ? ប្រាប់ខ្ញុំផង ក្រែងខ្ញុំជួយបានខ្លះ ។ សំបុត្រអាម៉ុំ និយាយស្អី ?

មិនមែនដូចនេះទេ ។ គូ រស់ ឯងជានារីគាប់ចិត្តរបស់ខ្ញុំ ។ តែ... ។ តែ...។ ណ្ហើយខ្ញុំមិននិយាយទេ ។ ថ្ងៃស្អែចាំដឹង ឥលូវយើងមើលទេសភាពវាប្រាំងម្តងវិញ ។ បើសំលេងខ្ញុំបានខ្ញុំរាប់ដើមឈើ រាប់ចាបដែលហើរទាំងហ្វូង ៗ នៅប្របព្រៃអោយ គូ រស់ ឯងស្តាប់...។

អា រស់ ៗ ( សំលេងមួយបានហៅ )

គូ រស់ អ្នកបងពេជ្រ ណារី គាត់ស្រែកហៅយើងហើយ ។ តស់យើងដើរទៅរកគាត់ ។

អ្នកទាំងពីរបានបណ្តើរគ្នាដើរ មករកអ្នក ពេជ្រណារី ហើយម៉ឹងបាននិយាយ ត ៖

ខ្ញុំចាំស្អែកមិនបានទេ ! គូ រស់ ដឹងទេស្អែកនេះ !

មានរឿងអ្វីចំលែក ?

ស្អែកនេះម៉ែខ្ញុំមកលេង ។ ព្រឹកស្អែកខ្ញុំ ត្រូវទៅមើលការអូរាំងអូវ...។ គូ រស់ ឯងមើលថែទាំគាត់ផង ។

ដំនឹងនេះបានធ្វើអោយអ្នកគ្រូ គូ រស់ សើចសប្បាយ លាន់មាត់ប្រាប់ទៅអ្នក ពេជ្រណារីថា ៖

គ្រាន់តែទៅមើលការអូរាំងអូរ ហើយស្នែកអឹំអញ្ជើញមកក៏ម៉ឹងខ្វល់ដែរអ្នកបង...។

សូមអ្នកបងទទួលពាក្យគាត់ផង ហើយសូមកុំអោយគាត់ពិបាកចិត្តពេក

ម៉េចខែពីសាខ រឺ កត្តិក ។ អាសាធទៅកុំអោយយូរពេក ។ ( អ្នកពេជ្រណារីបានជួយត្រេកអរ )

កុំថាមួយថ្ងៃ គង់តែមួយខែ ប្រាំខែ ក៏ខ្ញុំអាចមើលគាត់បានដែរ ។ ( អ្នកគ្រូ គូ រស់ បានឆ្លើយញញឹមដាក់ម៉ឹង ) ។

អរគុណនឹងសំដីនេះណាស់ ។ តស់យើងល្មមទៅផ្ទះថ្ងៃលិចហើយ... ( ម៉ឹងបានតឿន ) ។

អ្នកដើរកំសាន្តទាំងអស់ បាននាំគ្នាមកផ្ទះវិញ ។ អ្នកគ្រូ គូ រស់ បានចូលដើងក្រានចៀនចាប...។ ម៉ោង ៨ គេបាយរួចម៉ឹងបានលាទៅផ្ទះគាត់ ។

ដល់បន្ទប់ ម៉ឹងបានរៀបចំកំនាត់អង្រឹងភួយមុង ។ បន្ទាប់មកគាត់អង្គុយលើកៅអីមុខតុទាញបារី ដែលអ្នកគ្រូ គូ រស់ អោយមកជក់ រួចទាញដងប៉ាកាសរសេរថា ៖

គូ រស់ ស្ងួនភ្ងាបងសូមលា គូ រស់ពុំងាររនៅអោយសុខ
កុំព្រួយបារម្ភនាំកើតទុក្ខ នៅអោយបានសុខខំធ្វើការ ។
បងទៅតស៊ូដេញពួកខ្មាំង បារាំងអាមេរិចចក្រពត្រា
ព្រោះបើនៅយូរឃើញខកការ ចូលក្នុងបន្លាអន្ទាក់វា ។
ស្ថានការណ៍ស្រុកយើងរឹតចង្អៀត ខ្មាំងវាចេញស្មៀតគ្រប់កលការ
ចូលមកជ្រៀតជ្រែកប៉ងប្រាថ្នា ចាប់កៀបចាប់កៀររើសពលរេហ៍ ។
ឯករាជ្យក្លែងក្លាយចាប់ទាហាន បើយើងមិនហ៊ានរកផ្លូវទេ
មុខតែយើងស្លាប់ចោលកេរ្តិ៍ រក្សាពួកគេអោយបានខ្ពស់ ។

បងលា គូ រស់ ដោយអាក់អួល ចិត្តបងរមួលនឹក គូ រស់

តែទ្រាំនៅទៀតឃើញមិនរស់ បងលា គូ រស់ ឃ្លាតទៅឆ្ងាយ ។

គូ រស់នៅអោយគួរខំប្រឹង កុំនឹកទន្ទឹងទៅឯនាយ

ព្រោះការតស៊ូនៅវែងឆ្ងាយ ចក្រពត្តិមិនងាយចុះចាញ់វ៉ា ។

គូ រស់ប្អូននៅខំធ្វើការ ពង្រឹងស្មារតីអោយបានក្លា

កុំផ្អែកកុំពឹងលើវាសនា ត្រូវប្តេជ្ញារក្សាសិទ្ធិ ។

បងចេញទៅមុខខំប្រឹងឆ្ការ តស៊ូតវ៉ាទាមទារសិទ្ធិ

បងនឹងមកហៅរស់វរមិត្ត ចូលទៅរួមមិត្តជួយតស៊ូ ។

ម៉ឹង

សរសេរចប់ ម៉ឹង មើលហើយមើលទៀត ។ ដល់ម៉ោង ៩ មនុស្សប្រុសពីរនាក់បានចូលក្នុងបន្ទប់ម៉ឹង ។ ភ្ញៀវម្នាក់បានខ្សឹបប្រាប់ម៉ឹងថា " ដល់ពេលហើយយើងត្រូវទៅ " ។ ម្នាក់ទៀតបានយកកំនាត់អង្រឹងភួយមុង...។ ម៉ឹងបានច្រកសំបុត្រក្នុងស្រោមហើយដាក់ក្រោមពូក ។ បន្ទាប់មកគាត់ក៏បានចេញទៅតាមមនុស្សពីរនាក់នោះ...។

.....................................

# ១២ សន្តិភាព

ការតស៊ូប្រជាជនខ្មែរ វៀត ឡាវ បានជ័យជាលំដាប់ ។ សាមគ្គីរវាងប្រជាជនទាំងបីបានរីករាល់ថ្ងៃ ។ ប្រជាជនស្នេហាសន្តិភាពសាកលលោកបានជួយឧបត្ថម្ភដល់ការតស៊ូប្រជាជនយើង ។ ប្រជាជនបារាំងក៏បានប្រឆាំងជាខ្លាំងនឹងសង្គ្រាមនៅឥណ្ឌូចិន ។

នៅខែធ្នូ ១៩៥២ នៅវៀនធានីប្រទេសអូទ្រីសសមាជប្រជាជនសាកលលោកដើម្បីសន្តិភាពប្រជុំប្រតិភូ ១០០ ប្រទេសបានធ្វើសេចក្តីសំរេចចិត្តមួយបង្ខំរដ្ឋាភិបាល ចក្រពត្តិបារាំងអោយឈប់ជិះជាន់ប្រទេសខ្មែរ វៀត ឡាវ នឹងអោយប្រទេសទាំងបីបានឯករាជ្យសន្តិភាព ។

បន្ទាប់ពីនេះ មានការប្រជុំមហាអំនាចទាំងបួននៅក្រុងប៉ែរឡាំងពីភាក្សាដោះបញ្ហាឯកភាពអាឡឺម៉ង់ ។ ក្នុងពេលប្រជុំដើមឆ្នាំ ១៩៥៤ លោកម្ញូឡូតូ រដ្ឋមន្ត្រីបរទេសសូវៀតបានស្នើអោយមានសន្និសីទនៅ សឺណែវ ដើម្បីដោះបញ្ហាឥណ្ឌូចិន និង កូរ៉េ ហើយអោយមានចិនកុំមុយនីសចូលប្រជុំផង ។

សេចក្តីស្នើលោកម្ញូឡូតូ ព្រមនឹងការឧបត្ថម្ភប្រជាជនស្នេហាសន្តិភាពសាកលលោកព្រមនឹងកំលាំងប្រជាជនយើង ប្រឆាំងទល់នឹងអាណានិគមនឹងចក្រពត្តិនិយមបានអោយមានសន្និសីទនាក្រុង សឺណែវ ដែលចាប់ធ្វើពីថ្ងៃ ២៦ មេសា រៀងរហូតមកដល់ថ្ងៃ ២១ កក្កដា ១៩៥៤ ។ សន្និសីទបានសំរេចអោយជ័យជំនះមួយយ៉ាងទំហំមកប្រទេសខ្មែរ ឡាវ វៀតណាម អោយបានសន្តិភាពឯករាជ្យបោះឆ្នោតតាមបរបៀបប្រជាធិបតេយ្យ ។

កិច្ចព្រមព្រៀង សឺណែវបានធ្វើអោយប្រជាជនខ្មែរ ឡាវ បារាំង វៀតណាម និងប្រជាជនស្នេហាសន្តិភាពសាកលលោកត្រេកអរជាខ្លាំង ។ តែកិច្ចព្រមព្រៀងនេះធ្វើអោយពួកល្មោភសង្គ្រាមនេះតោឡោជាខ្លាំងដែរ ។ ចក្រពត្តិអាមេរិចកាំងក៏បានទូងស្គរស្រែកហៅមិត្តភ័ក្តិ និងដៃជើងរបស់គេអោយបង្កើតអង្គការសង្គ្រាមសេអាតូភ្លាម ហើយបោកបំភ័យគំរាមខ្មែរយើងអោយចូលធ្វើជាកូនទាហានរបស់គេ ។

ដោយកិច្ចព្រមព្រៀង សឺណែវ សូរសព្ទកាំភ្លើងតូចធំទាំងប៉ុន្មានបានឈប់លឺ ។ គ្រួសារប្រេកប្រេកបាក់ជិត ១០ ឆ្នាំបានជួបជុំគ្នាវិញខ្លះ ។ ម្តាយបានឃើញកូន ប្រពន្ធបានជួបប្តី ។ ល ។

មួយម្ដង ៗ ប្រជាជនដែលត្រូវកៀរបានវិលត្រលប់ទៅភូមិចាស់វិញ ។ មួយម្ដង ៗ ខ្មែរតស៊ូតែលប់ចូលមកពីគ្រប់ទិសនៃប្រទេសខ្មែរ ។ ឈ្លើយសឹកទាំងសងខាងក៏ត្រូវបានដោះលែង អ្នកជាប់គុកព្រោះតស៊ូនៅក្នុងបន្ទាយប្រមូលផ្ដុំកំពង់ចាមក៏ត្រូវបានលែង ។

លឹមដែលបានជូនដូងទៅស្វាយដូនកែវ ក៏បានត្រលប់មកភូមិអំពិលវិញ ។ អាចារ្យគឹមពូស្វាយ មីងពតអ្នកឃិន មីងអ៊ូ ត្រេកអរក៏ស្ទុះទៅទទួល ហើយលាន់មាត់គ្រប់គ្នាថា " កុំទៅណាវិញ ។ យកស្រែពូមីងខ្លះធ្វើទៅ...។

ជាដំបូងលឹមបានទៅវត្ត បង្សុកូលរំលឹកវិញ្ញាណក្ខន្ធ យាយម៉ុក តាង៉ែត នាងហេងព្រមទាំងមិត្រគាត់ច្រើនទៀតដែលបានចាកឋានក្នុងការតស៊ូ ។ លោកគ្រូម៉ក់សូត្រស្ដាំបានជួយជ្រុំជ្រែងបុណ្យបង្សុកូលយ៉ាងឧឡារិក ។

សឺឡែវសន្តិភាព ក៏បានបើកអោយពូផាន់ត្រលប់មកឃុំគោកចំបក់វិញ ។ គាត់ចេញចូលពីភូមិមួយទៅ ភូមិមួយដើរពន្យល់ប្រជាជនថា ៖

អាលឹមក្បត់ជាតិមកហើយ ។ វាមុខជាជាប់គុកមិនខានទេ ។ កុំស្ដាប់ កុំជឿវានិយាយអោយសោះ ។ ពួកវាស្អីក៏ សឺណែវ ដែរ ។ ម៉ូ ៗ លឺតែពង្រឹងពង្រីក ឯករាជ្យ អព្យាក្រឹតសន្តិភាព ។ លឺថាកិច្ចព្រមព្រៀងយោធាខ្មែរអាមេរិចអាក្រក់ ។ ចូរកុំស្ដាប់វាអោយលង់ខ្លួន តាមវាតិចថាផាន់មិនប្រាប់ ។ កុំបោះឆ្នោតអោយពួកវាអោយសោះ...។ សុទ្ធតែអាក្បត់ជាតិ អាកុំមុយនីស ។ ព្រោះតែវាបំផ្លាញជាតិដូចនេះហើយបានជាបេក្ខជន ពួកវានៅកំពង់ចាមត្រូវចាប់ឃុំ ។ អាលឹមគង់តែដល់វេនចូលគុកទេ...។ ពួកវានេះហើយដែលដុតត្រាបញ្ជីឃុំយើង ហើយបានព័ទ្ធបាញ់ខ្ញុំនិង ប៉ូលីសជា នៅទួលគោកត្រស់...។ ពួកវានេះហើយដែលបានដេញខ្ញុំអោយរត់ចោលតំនែងមេឃុំរត់ទៅពួននៅភ្នំពេញ...។

សឺណែវសន្តិភាពបានបំភ្លឺប្រជាជនខ្មែរអោយភ្ញាក់ អោយយល់នយោបាយក្នុងស្រុកនិងក្រៅប្រទេស ។ ឆន្ទៈ សន្តិភាព និង អព្យាក្រឹតភាពបានចាក់រាល់នាទីយ៉ាងជ្រៅទៅក្នុងមហាជន ។ ស្រីបាន មានសិទ្ធិដូចបុរស ។ អ្នកស្រុកនៅឃុំគោចំបក់បានភ្ញាក់រលឹកស្រលាញ់នយោបាយអព្យាក្រឹតនិងចេះរួបរួមគ្នាពិភាក្សាពីការបង្កើតសហករណ៍នៅក្នុងឃុំ ។ ពូផាន់បន្ទោស ជេរស្ដីលឹមដូចម្ដេច ក៏ប្រជាជនលែងជឿហើយមានខ្លះទៀតហ៊ានខ្វាស់ពូផាន់អោយទាល់ម្ដង ៗ នៅកណ្ដាលវត្តលោក ។

កំលាំងប្រជាជនស្អប់ខ្ពើមប្រឆាំងចក្រពត្តិនិយមអាមេរិចកាំង បានខ្ទប់មាត់ពូផាន់ព្រមទាំងបង្ខំគាត់អោយចេះនិយាយតាមអ្នកភូមិខ្លះផង ។

យើងត្រូវរួមសាមគ្គីគ្នា យើងត្រូវបំភ្លេចរឿងដើមចោល លឹមឯងខុសខ្លះ ពូក៏ខុសខ្លះ ។ យើងឈប់ជេរគ្នា ។ ពួកលឹមឯងមិនឈរឈ្មោះធ្វើបេក្ខជនសភាខេត្រទេនៅឃុំយើងនេះ...។ លឹមឯងជួយមែនទែន ។ តែលោកហុងឈ្នះស្រេចហើយ ។ គាត់ប៉ិនអែបជើងគេណាស់ កាលជប៉ុនគាត់ស្អិតជាមួយជប៉ុន ហើយឥលូវបែបត្រូវជាមួយអាមេរិចកាំងណាស់...។ ជាដាច់ខាតពូប្រឆាំងនឹងនយោបាយអាកាំងដែលអូសទាញយើងចូលសេអាតូ...។

តែចំពោះអ្នកគ្រូ គូ រស់ សីណែរបានអោយអ្នកអរព្រួយបារម្ភលាយចំរុះគ្នា ។ មុឹងដែលបានលាអ្នកទៅមិនឃើញត្រលប់មកវិញសោះ ។ ម៉ែ ឪ មុឹងបានចាំយូរឆ្នាំ ពីរឆ្នាំអស់សង្ឃឹមក៏ប្រាប់អ្នកគ្រូ គូ រស់ កុំអោយនៅចាំមុឹងទៀត ។ តែអ្នកគ្រូ គូ រស់ មិនបានដាច់ចិត្តភ្លាមទេ ។ អ្នកចេះតែនឹកចេះតែមើលសំបុត្រមុឹងដែលបានទុកអោយអ្នក កាលល្ងាចចេញទៅ ។ អ្នកដើរស៊ើបសួរដំនឹងមុឹងរាល់ថ្ងៃ រាល់ខែ...។ ឆ្នាំ ១៩៥៥ កន្លង ឆ្នាំ ១៩៥៦ មកដល់ ។ សាមគ្គីភាពរវាងប្រជាជនខ្មែរបានចំរើន ។ នយោបាយអព្យាក្រឹត ប្រជាជនខ្មែរបានលើទង់ជាតិខ្មែរអោយល្បីល្បាញសកលលោក ។ ចក្រពត្តិនិយមអាមេរិចកាំងប្រឆាំងហើយ ដើរគ្រប់មធ្យោបាយជ្រៀតជ្រែកបំបែកខ្មែរអោយបែកសាមគ្គីរវាងបក្សនិងបក្ស រវាងសមាជិកនិងសមាជិកក្នុងបក្ស ។ ប្រទេសកុំមុយនីស បានជួយឧបត្ថម្ភនយោបាយអព្យាក្រឹតខ្មែរ ។ ប្រទេសសហភាពសូវៀត ប៉ូឡូញ ឆេកូស្លូវ៉ាគី " យូគូស្លាវី " បានទទួលតំនាងប្រជាជនខ្មែរហើយបានរៀបចំដាក់ទូតទៅវិញទៅមក ។ សេចក្តីអស់សង្ឃឹមបានទុកកន្លែងអោយសេចក្តីសង្ឃឹម ។ អ្នកពេជ្រណារីបងជីដូនមួយអ្នកគ្រូ គូ រស់ បានដល់គូ ។ បុណ្យអាពាហ៍ពិពាហ៍បានរៀបចំធ្វើដោយរីករាយនៅខែពិសាខ ។ នៅថ្ងៃព្រឹកចូលរោងមនុស្សម្នាក់បាននាំសំបុត្រមួយច្បាប់មកជូនអ្នក ពេជ្រណារីមានសេចក្តីថា ៖

សូមគោរពអ្នកបងណារី

ខ្ញុំស្តាយជាខ្លាំងដោយមិនបានមកការអ្នកបងនៅថ្ងៃនេះ ។ សូមផ្ញើសំបុត្រនេះជូនពរអ្នកបងអោយបានប្រកបតែសេចក្តីចំរើនគ្រប់ប្រការ ។

មុឹង

សំបុត្រនេះបានធ្វើអោយថ្ងៃចូលរោង កាន់តែរីករាយសប្បាយទ្វេទៀត ។ អ្នកគ្រូ គូ រស់ អ្នកពេជ្រណារី ម៉ែ ឪ ម៉ឹងបានចោមរោមអ្នកនាំសំបុត្រសួរដំនឹងពីម៉ឹង ។ អ្នកនាំសំបុត្របានអោយការថា ៖

" ពីរខែក្រោយចេញពីព្រៃវែង ម៉ឹងបានឡើងទៅចលនានៅស្ទឹងត្រែង ។ ក្នុងការប្រតិបត្តិការគាត់បានជួបប្រយុទ្ធយ៉ាងខ្លាំងនឹងកងទ័ពបារាំង ។ ម៉ឹងត្រូវរបួសដៃឆ្វេង ហើយសព្វថ្ងៃនេះកំបុតដៃម្ខាង ។ ឥលូវគាត់នៅបង្កើនផលស្រុកលើ...។

ដំនឹងនេះបានពង្រីកមុខអ្នកគ្រូ គូ រស់ ធំជាងគេ ។ អ្នកគ្រូបានជជីកសួរអ្នកនាំសំបុត្រសព្វគ្រប់ហើយស្នើឡើងទៅជាមួយទៅជួបម៉ឹង ។ អ្នកនាំសំបុត្របានឃាត់ហើយសូមអោយអ្នកគ្រូសរសេរសំបុត្រទៅវិញ ។

អ្នកគ្រូ គូ រស់ បាននឹកអនុស្សាវរីយ៍គ្រប់សព្វ ហើយសរសេរសំបុត្រមួយផ្ញើទៅម៉ឹងថា ៖

ម៉ឹងភ្លេចគូ រស់ហើយ រឺ នៅ ចិត្តខ្ញុំមូលទៅម៉ឹងមិនភ្លេច
សំបុត្រក្រោមពូកខ្ញុំមើលរេច លាក់ទុកមិនភ្លេចក្នុងហោប៉ៅ ។
មើលញឹកវែងនឹកថែមចង់ជួប ចង់រួមចង់រូបចង់តាមទៅ
តែដោយមិនដឹងម៉ឹងដើរទៅ ជ្រកនៅព្រៃភ្នំរនាមណា ។
ទើបតែថ្ងៃនេះបានដំនឹង ថាម៉ឹងបាក់ដៃឆ្វេងពិការ
តែនៅដៃស្តាំគ្រាន់កាប់ឆ្ការ បង្កើនផលានៅស្រុកគេ ។
សូមម៉ឹងកុំព្រួយរឿងបាត់ដៃ ប្អូននៅអាល័យហើយសរសើរ
ស្រលាញ់ម៉ឹងឯងគ្មានអ្វីស្មើ ហើយខ្ញុំសូមស្នើម៉ឹងមកផ្ទះ ។

គូ រស់

រំលងមួយខែក្រោយអ្នកគ្រូ គូ រស់ បានទទួលសំបុត្រមួយច្បាប់មកវិញ ៖

គូ រស់ស្ងួនភ្ងាបងសែននឹក បងសូមរំលឹកគូ រស់ខ្លះ
សឺណែរសំរេចជ័យជំនះ ទំហំធំណាស់លើក្រដាស់ ។
យើងរួបរួមជាធ្លុងមួយ ស្រីប្រុសត្រូវជួយទាំងក្មេងចាស់
ត្រូវពួតដៃគ្នាយ៉ាងរហ័ស រួសរាន់បង្រះពីពួកខ្មាំង ។
រួចពីតស៊ូដេញបារាំង យើងត្រូវប្រឆាំងអាមេរិចកាំង
ដែលចូលជ្រៀតជ្រែកមកចាត់តាំង បង្កើនកំលាំងខាងជំនួយ ។
កលល្បិចខ្មាំងថ្មីជ្រៅណាស់អូន បើអស់បង់ប្អូនមិនខំជួយ
ព្រួតគ្នាដេញវាយើងជួបទុក្ខព្រួយ ព្រោះខ្មាំងវាជួយអូសទាញយើង ។
អោយចូលក្នុងពួកលោកសេរី ដែលជាបូរីបង្កភ្លើង
សង្គ្រាមដុតរោលងាប់ពួកយើង ដើម្បីតំលើងធនធានវា ។
ហេតុនេះយើងត្រូវស៊ូប្ដេជ្ញា ដេញវាអោយផុតដែនខេមរា
ទើបយើងបានក្សេមក្សាន្តក្នុងគ្រួសារ បានរស់រក្សាកូនតូចធំ ។
បងសូមគូ រស់ឆ្លៀតឱកាស នៅក្នុងឱកាសវ៉ាកងធំ
មកមើលមកលេងទន្លេធំ មករួមរៀបចំទ្រនំយើង ។

ម៉ឹង

**ចប់**

# កំនែពាក្យខុស

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| | | តចនិយម | តថនិយម |
| | | មេឃុំផាន | មេឃុំជា |
| | | ទូរណោរ | ទូរណោរ |
| | | សួរដំនឹងពីរកូន | សួរដំនឹងពីកូន |
| | | ភូយគរ | ភូយគ |
| | | ខ្មាស់ | ខ្មាស |
| | | ទោទារសំនង | ទៅទារសំនង |
| | | រកវាយ | រឹកវាយ |
| | | ភូយគរ | ភូយគ |
| | | ក្រោកពីលឹម | ក្រោយពីលឹម |
| | | កូនប្រសារ | កូនប្រសា |
| | | គុណដំបង | គុនដំបង |
| | | ផាន់បាន | ជាន់បាន |
| | | ប្រពទ្ធ | ប្រពន្ធ |
| | | កូនប្រសារ | កូនប្រសា |
| | | សន្លឹកយន្តហោះ | សន្ទឹកយន្តហោះ |
| | | គូរសំលាញ់ | គូសំលាញ់ |
| | | រិសផ្លូវ | រឹសផ្លូវ |
| | | គៀរ | កៀរ |
| | | តាឡេន | តាឡេង |
| | | ស្កាលីនក្រាត | ស្តាលីនក្រាត |
| | | និយាយផ្តាស់ | និយាយផ្តាស |
| | | បាន់ | បាន |
| | | នាំកចិន | នាំកចិន |
| | | គ្រេចអរ | គ្រេកអរ |
| | | ដំណឹង | ដំនឹង |
| | | ប្រកបាក់ជិត ១០ ឆ្នាំ | បែកបាក់ជិត ១០ ឆ្នាំ |

| | | | |
|---|---|---|---|
| | | ភូមិចាស់វញ<br>តែលប់ចូល<br>បង្សក្រូល<br>បង្សក្រូល<br>សឺឡៀវ<br>លើក្រដាស់ | ភូមិចាស់វិញ<br>ត្រលប់ចូល<br>បង្សុក្រូល<br>បង្សុក្រូល<br>សឺណោរ<br>លើក្រដាស |

# បញ្ជីអត្ថបទ

ទំព័រ

កថាមុខ

សេចក្តីប្រារព្ធ

អារម្ភកថា

១ មេឃុំផាន់

២ យប់មួយនៃគ្រួសារតាង៉ែត

៣ ប្រមូលកំនៃន

៤ ប្តូរផ្តាច់ដូចទាវ និង ឯក

៥ សង្គ្រាមចក្រពត្តិ

៦ កំនៃននៅពោធិចិនតុង

៧ ថ្ងៃបង្ហើយ

៨ សល់តែសំបកខ្លួន

៩ សំបុត្រ

១០ លាភូមិកំនើត

១១ ផ្លូវថ្មី

១២ សន្តិភាព

១៣ កំនៃពាក្យខុស

ករុណាខ្មែរ
ធ្វើទាន ដោះទុក្ខ កសាង

CAMBODIAN•EDUCATION•EXCELLENCE
មូលនិធិខ្មែរសម្រាប់ការសិក្សា
FOUNDATION